គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប – អង្គរ
ចូល ថ្ងៃទី 26 ខែ 05 ឆ្នាំ២025
ម៉ោង 10:45 AM

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ៣០ សសរ**

# សេចក្តីសម្រេច

# ស្តីពី

# ការដាក់ឱ្យអនុវត្តវិធានការគន្លឹះអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- បានឃើញអនុក្រឹត្យលេខ១៥៤ អនក្រ.បក ចុះថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ ._**

ត្រូវបានដាក់ឱ្យអនុវត្ត **វិធានការគន្លឹះអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥** ដែលជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២ ._**

គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ត្រូវត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តវិធានការគន្លឹះដូចបានកំណត់ក្នុងប្រការ១នៃសេចក្តីសម្រេចនេះ និងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលជាប្រចាំ ដើម្បីធានាការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**ប្រការ៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៤ ខែ មីនា ឆ្នាំ២០២៥

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ

# វិធានការគន្លឹះអភិវឌ្ឍន៍ទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥

| វិធានការ/សកម្មភាព | ក្របខណ្ឌពេលនៃការរៀបចំ | ស្ថាប័ននាំមុខរៀបចំនិងអនុវត្ត | ស្ថាប័នសហការអនុវត្ត |
|---|---|---|---|
| **យុទ្ធសាស្ត្រទី១ - ទាក់ទាញភ្ញៀវទេសចរអន្តរជាតិមកទស្សនាខេត្តសៀមរាប** | | | |
| **វិធានការគន្លឹះទី១ - ការផ្សព្វផ្សាយឱ្យស្គាល់ និងទាក់ទាញឱ្យមកទស្សនាខេត្តសៀមរាប** | | | |
| **វិធានការទី១ - លើកកម្ពស់រូបភាពខេត្តសៀមរាបជា "គោលដៅទេសចរណ៍វប្បធម៌ និងធម្មជាតិ"** | | | |
| ▪ ជំរុញការផ្សព្វផ្សាយគោលដៅទេសចរណ៍ក្នុងខេត្តសៀមរាបឱ្យបានទូលំទូលាយតាមគ្រប់រូបភាព និងគ្រប់មធ្យោបាយ៖ | | - ក្រសួងទេសចរណ៍/ ក.ផ.ផ. | - គ.អ.ទ.ស. / Sub-DMO<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - រៀបចំការប្រកួតប្រជែងថតរូបទេសចរណ៍ឆ្នើម ក្នុងព្រឹត្តិការណ៍សំខាន់ៗ(សមរាត្រី, អង្គរសង្ក្រាន្ត..) | មីនា/មេសា/ កញ្ញា | | |
| - ផ្សព្វផ្សាយអំពីទិដ្ឋភាពជាក់ស្តែង នៃភាពពេញចិត្តរបស់ភ្ញៀវទេសចរ និងរូបភាពវិជ្ជមាននានា | មករា - ធ្នូ | | |
| - ផ្សព្វផ្សាយជាវីដេអូខ្លីៗ និងបង្ហាញពីខ្លឹមសារឱ្យចំទីផ្សារគោលដៅ និងទាក់ទាញការមកទស្សនា។ | មករា - ធ្នូ | | |
| ▪ បង្កើនការយល់ឃើញជាវិជ្ជមានរបស់ភ្ញៀវទេសចរតាមថ្នាលបណ្តាញសង្គមល្បីៗ៖ | | - ក្រសួងទេសចរណ៍/ ក.ផ.ផ. | - គ.អ.ទ.ស. / Sub-DMO<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - បង្កើនការផ្សព្វផ្សាយ និងលើកកម្ពស់រូបភាពល្អៗ ដើម្បីលុបបំបាត់នូវការផ្សព្វផ្សាយនូវរូបភាពអវិជ្ជមាននិងព័ត៌មានមិនពិត | មករា - ធ្នូ | | |
| - ទាក់ទាញការរៀបចំកិច្ចប្រជុំកម្រិតតំបន់ កម្រិតអន្តរជាតិ ដើម្បីផ្សព្វផ្សាយពីរូបភាពវិជ្ជមានរបស់ខេត្តសៀមរាប | មេសា - ធ្នូ | | |

| | | | |
|---|---|---|---|
| - លើកទឹកចិត្តដល់អ្នកជំនាញការអន្តរជាតិ និងសាស្ត្រាចារ្យស្រាវជ្រាវល្បីៗ នៅក្នុងក្របខណ្ឌនៃ ICC Angkor និងក្របខណ្ឌផ្សេងទៀត ឱ្យជួយផ្សព្វផ្សាយពីរូបភាពវិជ្ជមាននិងគុណតម្លៃបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ នៅខេត្តសៀមរាប | មករា - ធ្នូ | | |
| - អញ្ជើញអ្នកសារព័ត៌មានក្នុងវិស័យធ្វើដំណើរ និងទេសចរណ៍ និងបុគ្គលដែលមានឥទ្ធិពល(KOLs), Influencers ក្នុងស្រុក និងមកពីទីផ្សារសំខាន់ៗ ដូចជា អាមេរិក អឺរ៉ុប ចិន ជប៉ុន កូរ៉េ អូស្ត្រាលី និងឥណ្ឌា ធ្វើទស្សនកិច្ចនៅតាមគោលដៅទេសចរណ៍អាទិភាពក្នុងខេត្តសៀមរាប | មេសា - ធ្នូ | | |
| - ជ្រើសរើស **"ទូតសុច្ឆន្ទៈ"** ដើម្បីផ្សព្វផ្សាយអំពីវិស័យទេសចរណ៍ខេត្តសៀមរាប | កុម្ភៈ - មេសា | | |
| - សហការជាមួយដៃគូពាណិជ្ជកម្មផ្នែកទេសចរណ៍ និង/ឬភ្នាក់ងារទេសចរណ៍អនឡាញ ដើម្បីលើកកម្ពស់ និងរក្សាកិត្តិនាមទេសចរណ៍ខេត្តសៀមរាប ទៅកាន់ពិភពលោក(ជាអាទិ៍ Tripadvisor, Agoda, Booking.com, Expedia សម្រាប់ទីផ្សារអាមេរិកនិងអឺរ៉ុប, Trip.com... ជាដើម) | កុម្ភៈ - មេសា | | |
| - បំផុស និងលើកទឹកចិត្តឱ្យប្រជាពលរដ្ឋខ្មែរនិងសហគមន៍ខ្មែរដែលរស់នៅក្រៅប្រទេស ចូលរួមផ្សព្វផ្សាយអំពីរូបភាពវិជ្ជមានរបស់ទឹកដីកំណើតខ្លួន និងផ្សព្វផ្សាយពីវប្បធម៌របស់ជាតិ តាមរយៈគណនីបណ្តាញសង្គមផ្ទាល់ខ្លួន (Facebook, YouTube, Tiktok, Instagram, X។ល។) | មករា - ធ្នូ | | |
| - ដាក់ចេញកម្មវិធីផ្សព្វផ្សាយឌីជីថលដោយឈរលើអភិក្រមនៃការចូលរួមផ្សព្វផ្សាយពីគ្រប់ភាគីពាក់ព័ន្ធ **"អាជីពណា ផ្សាយពីអាជីពនោះ"** និង **"អ្នកស្រុកណា ផ្សាយពីស្រុកនោះ"** ដែលតម្រូវឱ្យមានការធ្វើអក្ខរកម្មឌីជីថលដល់គ្រប់ភាគីពាក់ព័ន្ធ អំពីរបៀបរៀបចំខ្លឹមសារផ្សព្វផ្សាយ ការធ្វើទីផ្សារ វិធីសាស្ត្រ និងឧបករណ៍ផ្សព្វផ្សាយតាមគ្រប់ទម្រង់។ល។ ស្របតាមទស្សនាទាន **"ទេសចរណ៍ដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីទេសចរណ៍"** និង **"ម្នាក់ៗជាអ្នកផ្សព្វផ្សាយទេសចរណ៍កម្ពុជាម្នាក់"** | មករា - ធ្នូ | | |
| - ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីការទទួលបានជ័យលាភី ឬការទទួលស្គាល់ជាលក្ខណៈអន្តរជាតិនានារបស់គោលដៅទេសចរណ៍ខេត្តសៀមរាប (ឧទា.Tripadvisor, Lonely Planet...)។ | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| ▪ លើកកម្ពស់រូបភាពខេត្តសៀមរាបជាគោលដៅទេសចរណ៍មានភាពទាក់ទាញខ្ពស់ផ្នែកថ្លៃ៖ | | - ក្រសួងទេសចរណ៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - គ.អ.ទ.ស.<br>- អាជ្ញាធរជាតិអប្សរា<br>- ក្រ.ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - **ថ្លៃធ្វើដំណើរ** : (ឧទា. ធ្វើឱ្យតម្លៃសំបុត្រយន្តហោះប្រហាក់ប្រហែលនឹងប្រទេសជិតខាង[1] បន្តកាត់បន្ថយចំណាយដើមផ្សេងៗមិនចាំបាច់ សិក្សាលទ្ធភាពលើកទឹកចិត្តផ្នែកពន្ធដារសម្រាប់កញ្ចប់ទស្សនកិច្ចទេសចរណ៍។ល។) | មករា - ធ្នូ | | |
| - **ថ្លៃស្នាក់នៅ និងហូបចុក** : (ឧទា. លើកទឹកចិត្តឱ្យមានហាងម្ហូបអាហារច្រើនប្រភេទនិងថ្លៃសមរម្យ មានការអប់រំនិងការផ្សព្វផ្សាយថ្លៃឱ្យបានត្រឹមត្រូវ និងមានការទុកចិត្តពីភ្ញៀវ ការលក់វត្ថុអនុស្សាវរីយ៍ត្រូវផ្តល់បដិសណ្ឋារកិច្ចល្អនិងតម្លៃច្បាស់លាស់។ល។) | មករា - ធ្នូ | | |
| - **ថ្លៃសំបុត្រចូលទស្សនា** : (ឧទា. បំផុសចលនាពីវិស័យសាធារណៈនិងឯកជនលើយុទ្ធនាការ "**ថ្លៃ**" ដោយបង្កើតនូវ "**បណ្ណទស្សនាសៀមរាប**"។ល។) | មករា - មិថុនា | | |
| ▪ ផ្សព្វផ្សាយពីការអនុវត្តល្អ (Best Practice) នៃអាជីវកម្មទេសចរណ៍និងអាជីវកម្មពាក់ព័ន្ធក្នុងការអនុវត្តតាមស្តង់ដាជាតិនិងអន្តរជាតិលើការអភិវឌ្ឍប្រកបដោយចីរភាព៖ | | - ក្រសួងទេសចរណ៍ | - ក្រ.ពាក់ព័ន្ធ<br>- វិស័យឯកជន |
| - **កម្រិតថ្នាក់ជាតិ** : បំផុសការផ្សព្វផ្សាយពីអាជីវកម្មទេសចរណ៍ដែលទទួលបានជ័យលាភីក្នុងការអនុវត្តតាមស្តង់ដាបៃតង និងស្តង់ដាគុណភាពនានា | មករា - ធ្នូ | | |
| - **កម្រិតថ្នាក់តំបន់ និងអន្តរជាតិ** : បំផុសការផ្សព្វផ្សាយពីអាជីវកម្មទេសចរណ៍ដែលទទួលបានជ័យលាភី ឬការទទួលស្គាល់ជាលក្ខណៈអន្តរជាតិ។ | មករា - ធ្នូ | | |

[1] រាជរដ្ឋាភិបាលបានសម្រេចកាត់បន្ថយកម្រៃសិទ្ធិហោះហើរតែម្ខាង (Traffic Right Charge -Royalty) ដល់ក្រុមហ៊ុនអាកាសចរណ៍ដែលប្រតិបត្តិការជើងហោះហើរអន្តរជាតិនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ រួចហើយ។

| | | | |
|---|---|---|---|
| **វិធានការទី២ - ទាក់ទាញទីផ្សារទេសចរណ៍អាទិភាពមកកាន់ខេត្តសៀមរាប** | | | |
| ▪ រៀបចំផែនការទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២៥-២០២៨ ដោយសិក្សាកំណត់ប្រភពនិងប្រភេទទីផ្សារទេសចរណ៍សំខាន់ៗដែលមានសក្តានុពលសម្រាប់វិស័យទេសចរណ៍ខេត្តសៀមរាប | មករា - មីនា | - ក្រសួងទេសចរណ៍/ក.ផ.ផ. | - គ.អ.ទ.ស. / Sub-DMO<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| ▪ ទន្ទឹមនេះ ក្រៅពី**ទីផ្សារអឺរ៉ុប និងអាមេរិក** ដែលបានកើនឡើងដល់កម្រិតប្រហាក់ប្រហែលមុនវិបត្តិ ចំពោះមុខគួរចាប់យកប្រភពទីផ្សារទេសចរណ៍សំខាន់ៗបន្ថែមមកកាន់ខេត្តសៀមរាប ជាអាទិ៍ ទីផ្សារឥណ្ឌា ចិន ថៃ វៀតណាម ឡាវ កូរ៉េ ជប៉ុន និងអូស្ត្រាលី។<br>***សម្រាប់ទីផ្សារឥណ្ឌា៖*** | | - ក្រសួងទេសចរណ៍/ក.ផ.ផ. | -រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងមហាផ្ទៃ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- គ.អ.ទ.ស. / Sub-DMO<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - រៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់បែបទេសចរណ៍ជំនឿ ដោយផ្តោតលើការផ្សព្វផ្សាយ **"សៀមរាប ជាគោលដៅជំនឿសាសនា សម្រាប់ទេសចរឥណ្ឌា" (Pilgrimage Tourism)** | មករា - ធ្នូ | | |
| - រៀបចំកញ្ចប់ទស្សនកិច្ចសម្រាប់កម្មវិធីមុនអាពាហ៍ពិពាហ៍ កម្មវិធីអាពាហ៍ពិពាហ៍ និងក្រោយអាពាហ៍ពិពាហ៍ ដោយផ្តោតលើ **"សៀមរាប ជាគោលដៅផ្តល់ពរជ័យ និងសុភមង្គល"** | មករា - ធ្នូ | | |
| - បន្តរៀបចំទិវាអន្តរជាតិកីឡាយ៉ូហ្គា | មិថុនា | | |
| - ទាក់ទាញការវិនិយោគ និងពង្រឹងគុណភាពសេវាកម្មផ្នែកភោជនីយដ្ឋានលក់ម្ហូបឥណ្ឌា។ | មករា - ធ្នូ | | |
| ***សម្រាប់ទីផ្សារចិន៖*** | | | |
| - រៀបចំ Fam Trip សម្រាប់វិស័យឯកជន និង ក្រុមសារព័ត៌មានចិនល្បីៗមកខេត្តសៀមរាប | មេសា - កញ្ញា | | |
| - រៀបចំកម្មវិធី **"សៀមរាប ដោយជីវតាក្វាន់"** តាមសាកលវិទ្យាល័យនៅប្រទេសចិន ដែលមានកិច្ចសហការជាមួយកម្ពុជា (តំបន់ដែលមានអគ្គកុងស៊ុលកម្ពុជា) | មីនា - ឧសភា | | |
| - ពង្រឹងសមត្ថភាពភាសាចិនដល់មគ្គុទ្ទេសក៍និយាយភាសាចិន និងប្រតិបត្តិករ អមដោយចំណេះដឹងអំពីឥរិយាបថទេសចរជនជាតិចិន។ | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| <u>**សម្រាប់ទីផ្សារថៃ៖**</u> | | | |
| - រៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍តាមផ្លូវគោកនិងផ្លូវអាកាស ពីប្រទេសថៃ ដូចជា កញ្ចប់ទស្សនកិច្ចទេសចរណ៍សិក្សាស្រាវជ្រាវ កញ្ចប់ទស្សនកិច្ចមុននិងក្រោយអាពាហ៍ពិពាហ៍ ការលម្ហែប្រចាំឆ្នាំរបស់បុគ្គលិកក្រុមហ៊ុន (Incentive Program) កញ្ចប់ទស្សនកិច្ចរួមសៀមរាប ប៉ាតាយ៉ា សម្រាប់ទេសចរប្រទេសទី៣ | មករា - មេសា | | |
| - សិក្សាលទ្ធភាពចុះ MoU ជាមួយអាជ្ញាធរទេសចរណ៍ថៃ (TAT) និងអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីទទួលបានការគាំទ្របន្ថែមនិងជំរុញការអនុវត្ត។ | មករា - មីនា | | |
| <u>**សម្រាប់ទីផ្សារវៀតណាម៖**</u> | | | |
| - សិក្សាលទ្ធភាពចុះ MoU ជាមួយអាជ្ញាធរជាតិទេសចរណ៍វៀតណាម (VNAT) និងអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីទទួលបានការគាំទ្របន្ថែមនិងជំរុញការអនុវត្ត | មករា - មីនា | | |
| - សហការរៀបចំកញ្ចប់ទស្សនកិច្ចជាមួយប្រតិបត្តិករកម្ពុជា និងវៀតណាម | មករា - មីនា | | |
| - រៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍ តាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ពីវៀតណាម សៀមរាប-ហាឡុង សៀមរាប-ដាណាំង សៀមរាប-ភូកុក សៀមរាប-ហាណូយ សៀមរាប-ហូជីមិញ សម្រាប់ទេសចរប្រទេសទី៣។ | មករា - មីនា | | |
| <u>**សម្រាប់ទីផ្សារឡាវ៖**</u> | | | |
| - សិក្សាលទ្ធភាពចុះ MoU ជាមួយក្រសួងទេសចរណ៍ឡាវ និងអាជ្ញាធរខេត្តជាប់ព្រំដែន ដើម្បីទទួលបានការគាំទ្របន្ថែមនិងជំរុញការអនុវត្ត | មករា - មីនា | | |
| - សហការរៀបចំកញ្ចប់ទស្សនកិច្ចជាមួយប្រតិបត្តិករកម្ពុជានិងឡាវ | មករា - មីនា | | |
| - រៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍ តាមផ្លូវគោក និងផ្លូវអាកាស ពីឡាវ សៀមរាប- ហ្លួងប្រាបាង សម្រាប់ទេសចរប្រទេសទី៣។ | មករា - មីនា | | |

| | | | |
|---|---|---|---|
| **សម្រាប់ទីផ្សារកូរ៉េ៖** | | | |
| - រៀបចំផលិតផលទេសចរណ៍ថ្មីៗ ស្របតាមចំណាប់ចំណូលចិត្តទីផ្សារទេសចរណ៍កូរ៉េ | មករា - មិថុនា | | |
| - ទាក់ទាញផលិតកម្មកូរ៉េ មកថតកម្មវិធីទូរទស្សន៍ នៅតាមគោលដៅទេសចរណ៍សៀមរាប | មករា - ធ្នូ | | |
| - ពង្រឹងសមត្ថភាពមគ្គុទេសក៍ទេសចរណ៍និយាយភាសាកូរ៉េឱ្យបានច្រើននិងច្បាស់លាស់ | មករា - ធ្នូ | | |
| - រៀបចំ Fam Trip សម្រាប់វិស័យឯកជននិងក្រុមសារព័ត៌មានកូរ៉េល្បីៗមកខេត្តសៀមរាប។ | មេសា - កញ្ញា | | |
| **សម្រាប់ទីផ្សារជប៉ុន៖** | | | |
| - រៀបចំផលិតផលទេសចរណ៍ថ្មីៗ ស្របតាមចំណាប់ចំណូលចិត្តទីផ្សារទេសចរណ៍ជប៉ុន ដូចជាផលិតផលទេសចរណ៍ (MICE) ផលិតផលគិតគូរពីបរិស្ថាន។ល។ | មករា - មិថុនា | | |
| - រៀបចំ Fam Trip សម្រាប់វិស័យឯកជននិងក្រុមសារព័ត៌មានជប៉ុនល្បីៗមកខេត្តសៀមរាប | មេសា - កញ្ញា | | |
| - រៀបចំកម្មវិធីផ្លាស់ប្តូរបទពិសោធ ដូចជា ការរៀបចំដំណើរទស្សនកិច្ចសិក្សាស្វែងយល់វប្បធម៌ និងធម្មជាតិរបស់ខេត្តរវាងនិស្សិតជប៉ុននិងនិស្សិតខ្មែរ | មេសា - កញ្ញា | | |
| - ពង្រឹងសមត្ថភាពភាសាជប៉ុនដល់មគ្គុទ្ទេសក៍និយាយភាសាជប៉ុន និងប្រតិបត្តិករ ឱ្យបានច្រើននិងច្បាស់លាស់។ | មករា - ធ្នូ | | |
| **សម្រាប់ទីផ្សារអូស្ត្រាលី៖** | | | |
| - បន្តធ្វើការផ្សព្វផ្សាយទៅកាន់ទីផ្សារទេសចរណ៍អូស្ត្រាលី តាមរយៈការចូលរួមពិព័រណ៍នៅប្រទេសអូស្ត្រាលី | មករា - ធ្នូ | | |
| - ការរៀបចំ Fam Trip និង Tourism Road Show ដោយសហការជាមួយនឹងសភាពាណិជ្ជកម្មកម្ពុជា-អូស្ត្រាលី និងសមាគមខ្មែរនៅអូស្ត្រាលី | មករា - ធ្នូ | | |
| - ជំរុញឱ្យមានការហោះហើរត្រង់ពីអូស្ត្រាលីរបស់ក្រុមហ៊ុនអាកាសចរណ៍ Qantas ឬក្រុមហ៊ុនអាកាសចរណ៍ជាតិ Cambodia Angkor Air។ | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| សម្រាប់ទីផ្សារផ្ទៃក្នុងអាស៊ាន (Intra-ASEAN Travelers)÷ | | | |
| - ជំរុញ និងបង្កើនការតភ្ជាប់និងការហោះហើរពីបណ្តាប្រទេសក្នុងតំបន់អាស៊ានមកកាន់ខេត្តសៀមរាប (ឧទា. ការទាក់ទាញជើងហោះហើរថ្មីៗមកកាន់ខេត្តសៀមរាប ចូលរួមអនុវត្តបណ្តាកម្មវិធីក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទេសចរណ៍អាស៊ាន...) | មករា - ធ្នូ | | |
| - សហការរៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍ និងផ្សព្វផ្សាយរួមគ្នាជាមួយប្រទេសថៃ វៀតណាម ឡាវ និង/ឬ ប្រទេសក្នុងតំបន់ផ្សេងទៀត ក្រោមមូលបទ **"ប្រទេសពីរ គោលដៅទេសចរណ៍មួយ"** និង **"ប្រទេសបី/បួន គោលដៅទេសចរណ៍មួយ"** និងការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង | មករា - ធ្នូ | | |
| - បន្ធូរបន្ថយការធ្វើដំណើរ និងកាត់បន្ថយរបាំងមិនចាំបាច់ (ឧទា. សិក្សាការលើកលែងទិដ្ឋាការសម្រាប់ភ្ញៀវទេសចរបរទេសដែលរស់នៅឬធ្វើការក្នុងបណ្តាប្រទេសអាស៊ាន...)។ | មករា - ធ្នូ | | |
| ▪ ពង្រីកចំណែកទីផ្សារទេសចរណ៍អន្តរជាតិមកខេត្តសៀមរាប ដោយផ្តោតលើប្រភេទទីផ្សារទេសចរណ៍ថ្មីៗ (Niche Markets)៖<br>- គិតគូរបន្ថែមលើការរៀបចំសម្បទាទេសចរណ៍ និងការបង្កលក្ខណៈងាយស្រួលបន្ថែមទៀតដើម្បីទាក់ទាញទេសចរណ៍បែបសាសនានិងជំនឿ ទេសចរណ៍ម៉ាយ (MICE) ទេសចរដែលធ្វើការចល័តតាមឌីជីថល (Digital Nomad) ទេសចរណ៍កីឡា ទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍ ទេសចរណ៍តាមផ្លូវទឹក ទេសចរណ៍រៀបចំកម្មវិធីអាពាហ៍ពិពាហ៍។ល។ | មករា - កញ្ញា | - ក្រសួងទេសចរណ៍/ក.ផ.ផ. | - គ.អ.ទ.ស. / Sub-DMO<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| **វិធានការគន្លឹះទី២ - បង្កលក្ខណៈងាយស្រួលដល់ការសម្រេចចិត្ត និងការរៀបចំដំណើរទេសចរណ៍មកកាន់ខេត្តសៀមរាប** | | | |
| **វិធានការទី៣ - ពង្រឹងការផ្តល់ព័ត៌មានអំពីគោលដៅទេសចរណ៍ខេត្តសៀមរាបដល់ភ្ញៀវទេសចរអន្តរជាតិ** | | | |
| ▪ បង្កលក្ខណៈងាយស្រួលក្នុងការធ្វើការកក់ (Booking) មកខេត្តសៀមរាប៖ | | | |

| | | | |
|---|---|---|---|
| - តាមរយៈថ្នាលអនឡាញ : បង្កើនប្រសិទ្ធភាពនៃការស្វែងរកគេហទំព័រ និងថ្នាលឌីជីថលនានា ដែលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ខេត្តសៀមរាប នៅលើប្រព័ន្ធស្វែងរក ដូចជា Google, Baidu.com, Naver.com ជាដើម តាមរយៈវិធីសាស្ត្រ Search Engine Optimization (SEO) និង AI | មករា - ធ្នូ | - ក្រសួងទេសចរណ៍ / ក. ផ. ផ. | - គ.អ.ទ.ស. / Sub-DMO<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - តាមរយៈការីទេសចរណ៍ : ពង្រឹងការីទេសចរណ៍ ពិសេសការីទេសចរណ៍នាំភ្ញៀវចូលជាតិនិងអន្តរជាតិ មានសមត្ថភាពក្នុងការចូលទីផ្សារទេសចរណ៍ក្នុងតំបន់និងអន្តរជាតិ។ | មីនា - មិថុនា | | |
| ▪ សិក្សាផ្ដល់ការលើកទឹកចិត្ត (Incentives) ដល់ការីទេសចរណ៍ដែលបាននាំភ្ញៀវ មកទស្សនាខេត្តសៀមរាបច្រើនជាងគេ ប្រចាំឆ្នាំ២០២៥ | មីនា - មិថុនា | - ក្រសួងទេសចរណ៍ / ក. ផ. ផ. | - គ.អ.ទ.ស. / Sub-DMO<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| ▪ សហការពង្រឹងទំនាក់ទំនងជាមួយនឹងបណ្ដាស្ថានទូតនិងស្ថានតំណាងបរទេសប្រចាំកម្ពុជា ស្ថានតំណាងនៃព្រះរាជាណាចក្រកម្ពុជានៅបណ្ដាប្រទេសទីផ្សារទេសចរណ៍សំខាន់ៗ ដើម្បីផ្សព្វផ្សាយអំពីទេសចរណ៍ខេត្តសៀមរាប | មករា - ធ្នូ | - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | - ក្រសួងទេសចរណ៍/ ក. ផ. ផ.<br>- វិស័យឯកជន |
| ▪ ជំរុញការបង្កើតអនុព័ន្ធទេសចរណ៍អមស្ថានទូតកម្ពុជាប្រចាំនៅទីផ្សារទេសចរណ៍អាទិភាព (ចិន ជប៉ុន កូរ៉េ អាម៉េរិក ឥណ្ឌា អូស្ត្រាលី បារាំង អង់គ្លេស អាល្លឺម៉ង់...)។ | មករា - ធ្នូ | - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | - ក្រសួងទេសចរណ៍<br>- ក. ផ. ផ. |
| **វិធានការទី៤- បង្កើនការតភ្ជាប់ និងសហប្រតិបត្តិការទេសចរណ៍អន្តរជាតិ** | | | |
| ▪ **ផ្លូវអាកាស** : បង្កលក្ខណៈងាយស្រួលដល់ការចាប់យកប្រភពទីផ្សារទេសចរណ៍សំខាន់ៗ និងបង្កើនជើងហោះហើរត្រង់ពីប្រភពទីផ្សារអាទិភាព ឱ្យបានច្រើន មកកាន់ខេត្តសៀមរាបៈ | | | |
| - ជំរុញនិងទាក់ទាញក្រុមហ៊ុនអាកាសចរណ៍និងជើងហោះហើរថ្មីៗមកកាន់ខេត្តសៀមរាបឱ្យបានច្រើន ពិសេស "ថ្លៃទាប" (LCCs) តាមរយៈកម្មវិធីពិសេសសម្រាប់ឆ្នាំ២០២៥ ក្នុងនោះ ការបញ្ចុះថ្លៃ | មករា - មេសា | | |

| | | | |
|---|---|---|---|
| ចុះចត (Landing) ថ្លៃចំណត (Parking) ថ្លៃភ្លើងបំភ្លឺ (Lighting) និងថ្លៃស្ពានឆ្លងចូលយន្តហោះ នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ | | - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រុមហ៊ុនគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ<br>- ក្រុមហ៊ុនអាកាសចរណ៍ | - ក្រសួងទេសចរណ៍/ក. ផ. ផ.<br>- ក្រ. ពាក់ព័ន្ធ<br>- វិស័យឯកជន |
| - ការពង្រឹងក្រុមហ៊ុនអាកាសចរណ៍ជាតិ **"កម្ពុជាអង្គរអ៊ែរ"** និង/ឬ លើកទឹកចិត្តក្រុមហ៊ុនអាកាសចរណ៍ក្នុងស្រុក និង/ ឬ ក្រុមហ៊ុនអាកាសចរណ៍ Air Asia ហោះត្រង់ទៅកាន់សៀមរាប - ញូវដេលី សៀមរាប - បាលី សៀមរាប- បូរូបឌួ សៀមរាប - ម៉ាល់ឌីវ។ល។ | មករា - តុលា | | |
| - សិក្សាលទ្ធភាពបន្ធូរបន្ថយពន្ធប្រេងសាំងចាក់យន្តហោះនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ សម្រាប់ឆ្នាំ២០២៥ | មករា - មិថុនា | | |
| - ពិនិត្យឡើងវិញ និងសម្រួល Slot ម៉ោងហោះហើរតភ្ជាប់មកកាន់អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ឱ្យមានភាពទាក់ទាញជាងមុន។ | មករា - មីនា | | |
| ▪ **ផ្លូវគោក :** សម្រួលការធ្វើដំណើរដល់ភ្ញៀវទេសចរដែលឆ្លងកាត់តាមច្រកទ្វារព្រំដែនអន្តរជាតិផ្លូវគោក ចូលមកកម្ពុជា និងបន្តមកដល់គោលដៅខេត្តសៀមរាប ពិសេសនៅច្រកទ្វារប៉ោយប៉ែត និងអូរស្មាច់ ពីប្រទេសថៃ ច្រកទ្វារបាវិត ពីប្រទេសវៀតណាម និង ច្រកទ្វារត្រពាំងក្រៀល ពីប្រទេសឡាវ | | | - ក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា<br>- ក. ផ. ផ.<br>- ក្រុមហ៊ុនអាកាសចរណ៍<br>- ក្រ. ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តពាក់ព័ន្ធ<br>- វិស័យឯកជន |
| - ជំរុញចលនា **"ការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង"** សំដៅសម្រួលការធ្វើដំណើរទេសចរណ៍ពីបណ្ដាប្រទេសក្នុងតំបន់អាស៊ានចូលមកខេត្តសៀមរាបឱ្យកាន់តែប្រសើរថែមទៀត ក្នុងនោះត្រូវរៀបចំអនុក្រឹត្យស្ដីពី **"នីតិវិធីប្រតិបត្តិស្តង់ដា (SOP) ស្តីពីការធ្វើដំណើរទេសចរណ៍ដោយខ្លួនឯង"** | មករា - មេសា | - ក្រសួងទេសចរណ៍/គ. អ. ច. ទ.<br>- ក្រសួងមហាផ្ទៃ | |
| - សិក្សាលទ្ធភាពការផ្ដល់នូវបណ្ណធ្វើដំណើរ (Laissez-passer) សម្រាប់ប្រជាពលរដ្ឋថៃដែលរស់នៅខេត្តជាប់ព្រំដែនអាចចូលមកទស្សនាខេត្តសៀមរាប | មករា - ធ្នូ | | |
| - សម្រួលការធ្វើដំណើរចេញ- ចូលតាមផ្លូវអាកាស និងផ្លូវគោកឱ្យកាន់តែប្រសើរនិងងាយស្រួល ដោយបង្កើតជាកម្មវិធីពិសេស និងមានក្រុមការងារបដិសណ្ឋារកិច្ចពិសេសនៅច្រកទ្វារទាំងនោះ។ | មករា - ធ្នូ | | |

| វិធានការគន្លឹះទី៣ - បង្កលក្ខណៈងាយស្រួលក្នុងការមកដល់របស់ភ្ញៀវទេសចរនៅខេត្តសៀមរាប | | | |
|---|---|---|---|
| **វិធានការទី៥ - សម្រួលការធ្វើដំណើរទេសចរណ៍នៅតាមច្រកទ្វារអន្តរជាតិ** | | | |
| ▪ ជំរុញការបង្កលក្ខណៈងាយស្រួលនៅក្នុងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ដោយៈ | | - រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | - ក្រសួងមហាផ្ទៃ/អ.អ.<br>- អាជ្ញាធរជាតិអប្សរា<br>- អាកាសយានដ្ឋាន<br>- ក្រសួងទេសចរណ៍<br>- ក្រ.ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប |
| - សហការរៀបចំជាមួយ**ក្រុមហ៊ុនដែលមានជំនាញ**ក្នុងការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដើម្បីពង្រឹងការគ្រប់គ្រងនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ | មករា - មីនា | | |
| - បន្ថែមសម្បទា សេវាកម្ម និងផលិតផលនៅក្នុងអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ ដូចជាហាងលក់ទំនិញ ភោជនីយដ្ឋាន កន្លែងកម្សាន្ត កីឡា និងសួនកុមារ | មករា - ធ្នូ | | |
| - ពង្រឹងសមត្ថភាពមន្ត្រីនៅក្នុងអាកាសយានដ្ឋានក្នុងការផ្តល់សេវាកម្មនិងបដិសណ្ឋារកិច្ចល្អដល់ភ្ញៀវទេសចរ | មករា - ធ្នូ | | |
| - ពង្រឹងយន្តការគ្រប់គ្រងរថយន្តតាក់ស៊ី នៅ**អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ** (ធានាតម្លៃសមរម្យ) | មករា - ធ្នូ | | |
| - សម្រួលការធ្វើដំណើរភ្ញៀវទេសចរពីអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរទៅមកក្រុងសៀមរាប ក្នុងនោះជំរុញការពង្រីកផ្លូវចូលក្រុងសៀមរាប ចាប់ពីកន្លែងច្រកចូលអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរឆ្ពោះទៅក្រុងសៀមរាប | មករា - ធ្នូ | | |
| - បន្តចរចាឱ្យក្រុមហ៊ុនមិនយកថ្លៃផ្លូវចូលព្រលាន មិនយកប្រាក់សម្រាប់ការចូលដាក់ភ្ញៀវ[2] | មករា - មេសា | | |

[2] ការងារនេះ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានណែនាំរួចហើយកាលពីឆ្នាំ២០២៤។

| | | | |
|---|---|---|---|
| - ជំរុញការអនុវត្តគម្រោងរថភ្លើងធុនស្រាល (Tramway) ភ្ជាប់ពីអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ -រុនតាឯក -ក្រុងសៀមរាប | មករា - ធ្នូ | | |
| - សិក្សាផ្លូវតភ្ជាប់ពីអាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ- រុនតាឯក- តំបន់អង្គរ-ក្រុងសៀមរាប។ | មករា - មេសា | | |
| ▪ ជំរុញការបង្កលក្ខណៈងាយស្រួលតាមច្រកចូលផ្លូវគោក ដោយ៖ | | - ក្រសួងមហាផ្ទៃ/អ.អ.<br>- ក្រសួងទេសចរណ៍/គ.អ.ច.ទ. | - រដ្ឋបាលខេត្តពាក់ព័ន្ធ<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- វិស័យឯកជន |
| - បង្កលក្ខណៈងាយស្រួលដល់ការធ្វើដំណើរទេសចរណ៍នៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត អូរស្មាច់ បាវិត និងត្រពាំងក្រៀល ដោយបង្កើតឱ្យមានក្រុមបដិសណ្ឋារកិច្ចពិសេស និង Lane ពិសេស | មករា - ធ្នូ | | |
| - ពង្រឹងការគ្រប់គ្រងរថយន្តដឹកភ្ញៀវទេសចរពីច្រកទ្វារទាំងនេះមកក្រុងសៀមរាប លើទិដ្ឋភាពតម្លៃ គុណភាព និងសុវត្ថិភាព។ | មករា - ធ្នូ | | |
| **វិធានការគន្លឹះទី៤ - សម្រួលដល់ដំណើរកម្សាន្តក្នុងខេត្តសៀមរាប ស្របតាមទិសស្លោក "សៀមរាប៖ តារានៃទិសខាងកើត"** | | | |
| **វិធានការទី៦ - ពិពិធកម្មគោលដៅទេសចរណ៍នៅតាមតំបន់អាទិភាពទាំង៦** | | | |
| ▪ កសាងនិងកែលម្អឱ្យកាន់តែប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាគាំទ្រទេសចរណ៍ នៅតាមគោលដៅអាទិភាពដូចខាងក្រោម៖ | | | |
| **<u>១- តំបន់បេតិកភណ្ឌអង្គរ៖</u>** | | - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា | - គ.អ.ទ.ស.<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ<br>- រដ្ឋបាលខេត្តសៀមរាប<br>- ក្រសួង[illegible] |
| - បន្តលើកទឹកចិត្ត និងសម្រួលនូវលក្ខខណ្ឌតម្រូវថ្មីពាក់ព័ន្ធនឹងការថតវីដេអូឬរូបភាពសន្លឹកក្នុងតំបន់រមណីយដ្ឋានអង្គរ[3] | មករា - ធ្នូ | | |
| - សិក្សាបង្កើនវង់ទស្សនាប្រាសាទឱ្យមានច្រើនជម្រើសសម្រាប់ភ្ញៀវទេសចរ | មករា - មិថុនា | | |
| - រៀបចំផែនការសេវាកម្មដឹកជញ្ជូនទេសចរណ៍ក្នុងតំបន់អង្គរ | មករា - ធ្នូ | | |
| - សិក្សារៀបចំឱ្យមានសេវាកម្មអាហារនិងភេសជ្ជៈ (F&B) នៅតាមទីតាំងជាក់លាក់មួយចំនួននៅក្នុងតំបន់អង្គរ ដោយត្រូវអនុលោមតាមសៀវភៅបន្ទុកច្បាស់លាស់ពីអាជ្ញាធរជាតិអប្សរា | មករា - មេសា | | |

[3] អាជ្ញាធរជាតិអប្សរាបាននិងកំពុងកែសម្រួលការងារនេះ ក្រោយ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** បានណែនាំ។

| | | | |
|---|---|---|---|
| - ថែរក្សាភាពស្អាត អនាម័យ សន្តិសុខ និងសណ្តាប់ធ្នាប់ | មករា - ធ្នូ | | - ក្រ. ពាក់ព័ន្ធ<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍ |
| - បង្កើនការផ្សព្វផ្សាយអំពីប្រភេទប្រាសាទ ឬក្រុមប្រាសាទ ដែលអនុញ្ញាតឱ្យរៀបចំព្រឹត្តិការណ៍ទេសចរណ៍និងវប្បធម៌ | មករា - ធ្នូ | | |
| - ពង្រឹងការគ្រប់គ្រងសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ : ដើម្បីឱ្យការគ្រប់គ្រងសេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍បានល្អប្រសើរ ត្រូវឆ្លងកាត់វគ្គបណ្តុះបណ្តាលវិក្រឹតការពិសេស ដែលទទួលស្គាល់ដោយក្រសួងទេសចរណ៍និងអាជ្ញាធរជាតិអប្សរា | មករា - ធ្នូ | | |
| - បន្តរៀបចំដាក់ភ្លើងបំភ្លឺពេលយប់នៅតាមផ្លូវសំខាន់ៗក្នុងតំបន់អង្គរ | មករា - ធ្នូ | | |
| - រៀបចំព្រឹត្តិការណ៍ និងផលិតផលទេសចរណ៍ថ្មីៗបន្ថែម អនុលោមតាមគោលការណ៍នៃទេសចរណ៍វប្បធម៌ - ទេសចរណ៍បៃតង | មករា - ធ្នូ | | |
| - បន្តការអនុវត្តការកែសម្រួលពេលវេលាបើក- បិទ នៃការចូលទស្សនាប្រាសាទក្នុងរមណីយដ្ឋានអង្គរ និងសិក្សាលទ្ធភាពកែសម្រួលពេលវេលាបើក - បិទផ្សេងៗទៀត ដោយផ្អែកលើតម្រូវការជាក់ស្តែងរបស់ភ្ញៀវទេសចរ[3] | មករា - ធ្នូ | | |
| - រៀបចំបញ្ជរព័ត៌មានទេសចរណ៍ អមជាមួយការបំពាក់សម្ភារៈឱ្យបានគ្រប់គ្រាន់ | មករា - តុលា | | |
| - បន្តពង្រឹងការធ្វើពិពិធកម្មសកម្មភាពបម្រើឱ្យទេសចរណ៍ក្នុងតំបន់អង្គរ ឱ្យកាន់តែមានភាពសម្បូរបែប ស្របតាមតម្រូវការថ្មីៗរបស់ភ្ញៀវទេសចរគ្រប់កម្រិត ដោយប្រកាន់ខ្ជាប់នូវគោលការណ៍ "**ការអភិរក្សគាំទ្រដល់ការអភិវឌ្ឍ ហើយការអភិវឌ្ឍបម្រើដល់ការអភិរក្ស**"។ | មករា - ធ្នូ | | |
| - **ឌីជីថលអង្គរ** (Digital Angkor)៖ | | - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/ អាជ្ញាធរជាតិអប្សរា<br>- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | - គ. អ. ទ. ស.<br>- រដ[illegible]ប<br>- ក្រ. ពាក់ព័ន្ធ |
| • បន្តធ្វើទំនើបកម្ម កម្មវិធីទូរសព្ទ Visit Angkor ដើម្បីផ្សព្វផ្សាយពីវង់ទស្សនាប្រាសាទគោលដៅទេសចរណ៍ និងផលិតផលទេសចរណ៍ថ្មីៗនៅក្នុងតំបន់រមណីយដ្ឋានអង្គរ | មករា - ធ្នូ | | |
| • ជំរុញការអនុវត្តគម្រោងបង្កើតសារមន្ទីរ Immersive Angkor | មករា - ធ្នូ | | |
| • សិក្សាលទ្ធភាពដាក់ឱ្យដំណើរការ "**សារមន្ទីរសព្វទស្សន៍អង្គរ**" (Angkor Panorama) | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| • បន្តជំរុញទំនើបកម្មប្រព័ន្ធគ្រប់គ្រងការលក់សំបុត្ររបស់គ្រឹះស្ថានអង្គរ ដែលប្រព័ន្ធនេះអាចជួយដល់ការគ្រប់គ្រងទិន្នន័យរំហូររបស់ភ្ញៀវទេសចរ | មករា - ធ្នូ | - គ្រឹះស្ថានអង្គរ<br>- ក្រុមហ៊ុន Immersive Angkor | |
| • ជំរុញសេវាទូរគមនាគមន៍ក្នុងតំបន់អង្គរ។ | មករា - ធ្នូ | | |
| **២- ក្រុងសៀមរាប៖** | | - អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ក្រុងសៀមរាប<br>- គ.អ.ទ.ស. | - ក្រសួងទេសចរណ៍<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/ អាជ្ញាធរជាតិអប្សរា<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- ក្រ.ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍ |
| - រៀបចំកែលម្អស្ទឹងសៀមរាប (ផ្នែកកណ្តាល) ជាកន្លែងកម្សាន្តទេសចរណ៍ | មករា - ធ្នូ | | |
| - រៀបចំ "**សង្កាត់ទេសចរណ៍គំរូ**" នៅក្រុងសៀមរាប ផ្សារភ្ជាប់នឹងការរៀបចំវត្តទេសចរណ៍ | មករា - ធ្នូ | | |
| - រៀបចំវិថីម្ហូបអាហារនិងផ្សាររាត្រីឱ្យមានភាពទាក់ទាញ | មករា - ធ្នូ | | |
| - ពង្រឹងភាពស្អាតនិងបៃតង | មករា - ធ្នូ | | |
| - ពង្រឹងសណ្តាប់ធ្នាប់តាមផ្លូវក្នុងទីក្រុង ចំណតរថយន្ត និងចំណតរ៉ឺម៉កកង់បី | មករា - មេសា | | |
| - តុបតែងលម្អក្នុងទីក្រុង | មករា - ធ្នូ | | |
| - ទំនើបកម្មសេវាកម្មមណ្ឌលព័ត៌មានទេសចរណ៍ | មករា - មិថុនា | | |
| - ពង្រឹងគុណភាពសេវាហាងលក់ទំនិញ វត្ថុអនុស្សាវរីយ៍ ពិសេសត្បូងមានតម្លៃ តាមរយៈការបង្កើតយន្តការគ្រប់គ្រងច្បាស់លាស់ ដើម្បីធានាទំនុកចិត្តដល់ភ្ញៀវទេសចរ | មករា - មេសា | | |
| - គិតគូរលើសម្បទាទាក់ទាញប្រភេទទេសចរណ៍ Digital Nomad (Co-Working Spaces និងប្រភេទទិដ្ឋាការពិសេស) | មករា - កញ្ញា | | |
| - សិក្សានិងកំណត់ទីតាំងរៀបចំតំបន់ (zoning) សេវាកម្មមណ្ឌលកម្សាន្តមនុស្សពេញវ័យ។ | មករា - កញ្ញា | | |
| **៣- តំបន់បឹងទន្លេសាប (ពិសេសនៅចុងឃ្នៀស កំពង់ភ្លុក កំពង់ឃ្លាំង និងបឹងពារាំង (ជ្រាវ))៖** | | - អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់បឹងទន្លេសាប<br>- គ.អ.ទ.ស. | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ<br>- ក្រសួងទេសចរណ៍<br>អាជ្ញាធរជាតិទន្លេសាប |
| - សិក្សាគម្រោងកែលម្អផ្លូវចូលទៅសហគមន៍ចុងឃ្នៀស កំពង់ភ្លុក បឹងពារាំង និងកំពង់ឃ្លាំង | មករា - ធ្នូ | | |
| - កែលម្អទូកទេសចរណ៍នៅតំបន់បឹងទន្លេសាប ជាជំហានៗ ស្របតាមតម្រូវការនិងសំណូមពរជាច្រើនពីភ្ញៀវទេសចរ ក៏ដូចជាសហគមន៍ដែលជាអ្នកផ្គត់ផ្គង់សេវាទូកទេសចរណ៍នេះផ្ទាល់តែម្តង | មករា - ធ្នូ | | |
| - ពង្រឹងសហគមន៍ ទាំងធនធាននិងសមត្ថភាពក្នុងការទទួលស្វាគមន៍ភ្ញៀវ | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| - បញ្ចុះតម្លៃទូកសម្រាប់ភ្ញៀវក្នុងស្រុកនៅចុងឃ្នៀស[4] | កុម្ភៈ - ឧសភា | | - អាជ្ញាធរទន្លេសាប<br>- ក្រ.ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប<br>-សហគមន៍<br>-វិស័យឯកជន<br>-ដៃគូអភិវឌ្ឍ |
| - ជំរុញសកម្មភាពសិប្បកម្មងាយៗនៅតាមសហគមន៍ | កុម្ភៈ - ឧសភា | | |
| - សិក្សារៀបចំប្រព័ន្ធបង់រំលស់ទូកទេសចរណ៍នៅក្នុងសហគមន៍ទេសចរណ៍ក្នុងតំបន់បឹងទន្លេសាប (ដោយមានការផ្ដល់ការធានាពីរដ្ឋ អមជាមួយការកំណត់នូវលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការធានាច្បាស់លាស់) | កុម្ភៈ - ឧសភា | | |
| - រៀបចំឱ្យមានទីតាំងថតរូបអនុស្សាវរីយ៍ ជាមួយទេសភាពស្អាតៗ | មេសា - កញ្ញា | | |
| - ពង្រឹងការគ្រប់គ្រងសំរាម សំណល់រឹង-រាវ | មករា - ធ្នូ | | |
| - រៀបចំឱ្យមានការសម្ដែងទស្សនីយភាពផ្សេងៗ ឬបុណ្យប្រពៃណីប្រចាំតំបន់ ឬព្រឹត្តិការណ៍ផ្សេងៗ។ | មករា - ធ្នូ | | |
| **<u>៤- តំបន់ឧទ្យានជាតិភ្នំគូលែនៈ</u>** | | | |
| - ដាក់ឱ្យដំណើរការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ភ្នំគូលែន | មករា - កុម្ភៈ | - អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម-“ភ្នំគូលែន”<br>- គ.អ.ទ.ស. | - ឧ.ជ.ភ.គ.<br>- រដ្ឋបាលខេត្តសៀមរាប<br>- ក្រសួងបរិស្ថាន<br>- ក្រសួងទេសចរណ៍<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា<br>- ក្រ. ពាក់ព័ន្ធ<br>- ក្រុមហ៊ុនទទួលសិទ្ធិ<br>- សហគមន៍<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍ |
| - រៀបចំសណ្ដាប់ធ្នាប់ | មករា - ធ្នូ | | |
| - កែលម្អផ្លូវឡើង និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ (ដូចជា ខ្សែ-តូបអាហារ រៀបចំមណ្ឌលព័ត៌មានទេសចរណ៍នៅជើងភ្នំ កែលម្អបន្ទប់ទឹកនៅលើភ្នំ គ្រប់គ្រងសំរាម) | មករា - ធ្នូ | | |
| - រៀបចំផ្លូវទស្សនាចរណ៍បន្ថែម ទៅកាន់ទីតាំងធម្មជាតិនិងវប្បធម៌ | មករា - ធ្នូ | | |
| - ពិពិធកម្មផលិតផល និងសេវាទេសចរណ៍ រួមទាំងសហគមន៍ព្រៃធំអន្លង់ធំ និងសហគមន៍ព្រៃធំពពេល | មករា - ធ្នូ | | |
| - រៀបចំបង្កើតមណ្ឌលវិបស្សនា ឬសមាធិ ឱ្យមានមាត្រដ្ឋានជាទីជ្រះថ្លា នៅតំបន់ភ្នំគូលែន | មករា - ធ្នូ | | |
| - ពង្រឹងសមត្ថភាពសហគមន៍ ពិសេសគុណភាពសេវាកម្ម | មករា - ធ្នូ | | |
| - សិក្សាសម្រួលថ្លៃសំបុត្រចូលទស្សនា | មករា - មិថុនា | | |
| - បំពាក់សេវាទូរគមនាគមន៍។ | មករា - ធ្នូ | | |

[4] គ្រឹះស្ថានអង្គរបាននិងកំពុងកែសម្រួលការងារនេះ ក្រោយទទួលបានការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាធិបតីនាយករដ្ឋមន្ត្រី**។

| | | | |
|---|---|---|---|
| **<u>៥- តំបន់ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី៖</u>** | | - អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ទេសចរណ៍ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី<br>- គ.អ.ទ.ស. | - ក្រសួងទេសចរណ៍<br>- ក្រ.ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - ដាក់ឱ្យដំណើរការអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍តំបន់ជុំវិញតំបន់ការពារប្រាសាទបន្ទាយស្រី | មករា - កុម្ភៈ | | |
| - ការកែលម្អផ្លូវទៅបន្ទាយស្រី | មករា - ធ្នូ | | |
| - ផ្សារភ្ជាប់ការអភិវឌ្ឍជាមួយក្រុងរុនតាឯកតេជោសែន | មករា - ធ្នូ | | |
| - ការរៀបចំភូមិទេសចរណ៍គំរូ (ដាក់ភូមិព្រះដាក់ជាភូមិទេសចរណ៍ឆ្នើមនៃអង្គការទេសចរណ៍ពិភពលោក - UN Tourism) | មករា - ធ្នូ | | |
| - ការពង្រឹងសហគមន៍។ | មករា - ធ្នូ | | |
| **<u>៦- តំបន់ទេសចរណ៍សៀមរាបថ្មី - ក្រុងរុនតាឯកតេជោសែន៖</u>** | | - គ.អ.រ.ព.ស.<br>- គ.អ.ទ.ស. | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តសៀមរាប<br>- ក្រ.ពាក់ព័ន្ធ |
| - សិក្សាសមាហរណកម្មតំបន់ទេសចរណ៍សៀមរាបថ្មី ចូលក្នុងគម្រោងអភិវឌ្ឍន៍ក្រុងរុនតាឯកតេជោសែន | មិថុនា - ធ្នូ | | |
| - រៀបចំគម្រោងសាកល្បងលើការរៀបចំភូមិទេសចរណ៍នៅក្នុងក្រុងរុនតាឯកតេជោសែន។ | កញ្ញា - ធ្នូ | | |
| ▪ សិក្សាលទ្ធភាពកែលម្អហេដ្ឋារចនាសម្ព័ន្ធទៅកាន់គោលដៅទេសចរណ៍ និងបំពាក់បន្ថែមនូវសម្បទាទ្រទ្រង់នៅក្នុងក្រុងនិងផ្លូវទៅកាន់គោលដៅសំខាន់ៗ ជាអាទិ៍ ភ្លើងបំភ្លឺផ្លូវ បំពាក់ស្លាកសញ្ញាដូចខាងក្រោម៖ | | - Sub-DMO<br>- គ.អ.ទ.ស. | - ក្រសួងសាធារណការនិងដឹកជញ្ជូន<br>- រដ្ឋបាលខេត្តសៀមរាប<br>- អាជ្ញាធរទន្លេសាប<br>- ក្រ.ពាក់ព័ន្ធ<br>- ដៃគូអភិវឌ្ឍ |
| - **កំពង់ផែចុងឃ្នៀស : ១)-** ផ្លូវទឹកសម្រាប់កាណូតដឹកភ្ញៀវទេសចរនៅរដូវប្រាំង ទំហំទទឹង១២ម៉ និងបណ្តោយ៤០០០ម៉ ដោយត្រូវជីកស្តារជម្រៅ២ម៉ែត្របន្ថែមទៀត **២)-** ចំណតរថយន្តមានទំហំ៣០ម៉ និងបណ្តោយ៥០ម៉ (តូចចង្អៀត) និង **៣)-** ចំណតកាណូតនិងទូកមានទំហំតូចចង្អៀតនៅរដូវប្រាំងនិងរដូវវស្សា។ | មករា - មេសា | | |

| | | | |
|---|---|---|---|
| - **សហគមន៍ទេសចរណ៍កំពង់ភ្លុក : ១)-** រៀបចំផ្លូវបេតុង១ខ្សែ ប្រវែង១៤គ.ម ចាប់ពីស្ពានទំនប់ទឹកវត្តរការហូតដល់ស្ពានដើមរាំងមួយដើម **២)-** រៀបចំមណ្ឌលព័ត៌មានសម្រាប់ដាក់តាំងឧបករណ៍នេសាទផ្សេងៗទៀត **៣)-** រៀបចំចំណតកាណូតនិងចំណតរថយន្ត១កន្លែង សម្រាប់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ប្រវែង(២០០មx២០០ម) **៤)-** រៀបចំបង្គន់អនាម័យចំនួន៦នៅកន្លែងលក់សំបុត្រ **៥)-** រៀបចំបង្គន់អនាម័យចំនួន៦នៅចំណតរថយន្ត **៦)-** រៀបចំសួនច្បារ១កន្លែង នៅក្បែរចំណតរថយន្តសម្រាប់ភ្ញៀវទេសចរ **៧)-** រៀបចំបច្ចេកទេសក្នុងការទុកដាក់សំរាម។ | មករា - មេសា | | |
| - **រមណីយដ្ឋានទឹកធ្លាក់ភ្នំគូលែននិងព្រះអង្គធំ** : ផ្លូវបេតុងប្រវែង១ ០០០ម៉ែត្រ ចំណតរថយន្តទំហំ៥០ម x១០០ម បន្ទប់ទឹកចំនួន២០បន្ទប់។ | មករា - មេសា | | |
| ▪ សិក្សាគម្រោងប្លង់លម្អិតកែលម្អគោលដៅទេសចរណ៍អាទិភាព ដូចជា គម្រោងអភិវឌ្ឍន៍សង្កាត់ទេសចរណ៍គំរូក្រុងសៀមរាប (ផ្សារចាស់ វត្តរាជបូណ៌ និងវត្តព្រះព្រហ្មរ័ត្ន) គម្រោងលើកកម្ពស់ភាពទាក់ទាញទេសចរណ៍នៅតំបន់ចុងឃ្នៀស គម្រោងលើកកម្ពស់ភាពទាក់ទាញទេសចរណ៍នៅសហគមន៍ទេសចរណ៍ធម្មជាតិកំពង់ភ្លុក គម្រោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម- "ភ្នំគូលែន" និងគម្រោងអភិវឌ្ឍន៍ផ្សាររាត្រីនិងវិថីម្ហូបអាហារ | មករា - ធ្នូ | - គ.អ.ទ.ស. | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ទីស្តីការគណៈរដ្ឋមន្ត្រី<br>- Sub-DMO<br>- ក្រ. ពាក់ព័ន្ធ<br>- វិស័យឯកជន |
| ▪ សិក្សាគោលនយោបាយអនុគ្រោះបន្ថែមដល់ការវិនិយោគបង្កើតផលិតផលនិងសេវាកម្មទេសចរណ៍ថ្មីៗនៅខេត្តសៀមរាប ដោយផ្តល់អាទិភាពសម្រាប់រមណីយដ្ឋានកែច្នៃ អាជីវកម្មភោជនីយដ្ឋានកម្រិតស្តង់ដាខ្ពស់ ដូចជា ភោជនីយដ្ឋានចិន ឥណ្ឌា ជប៉ុន កូរ៉េ អឺរ៉ុប និងហាលឡាល់ នៅខេត្តសៀមរាប | មករា - មិថុនា | - ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | - រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| ▪ សិក្សាស្វែងរកដៃគូវិនិយោគបង្កើតតំបន់ទេសចរណ៍ពិសិដ្ឋនៅក្នុងខេត្តសៀមរាប។ | មករា - ធ្នូ | - ក្រសួងទេសចរណ៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- គ.អ.ទ.ស. | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |

| | | | |
|---|---|---|---|
| **វិធានការទី៧ - ពង្រឹងយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍គោលដៅទេសចរណ៍អាទិភាព** | | | |
| ▪ រៀបចំនិងពង្រឹងយន្តការគ្រប់គ្រងកម្រៃចូលទស្សនានៅតាមគោលដៅទេសចរណ៍អាទិភាពទាំងអស់ | មករា - មិថុនា | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ<br>- គ.អ.ទ.ស.<br>- រដ្ឋបាលខេត្តសៀមរាប | - សហគមន៍<br>- វិស័យឯកជន |
| ▪ ពិនិត្យឡើងវិញនូវគោលនយោបាយសំបុត្រអង្គរឱ្យស្របតាមនិន្នាការទេសចរណ៍ និងបរិបទជាក់ស្តែង | មករា - មីនា | - គ្រឹះស្ថានអង្គរ | - អាជ្ញាធរជាតិអប្សរា<br>- គ.អ.ទ.ស.<br>- រដ្ឋបាលខេត្តសៀមរាប |
| ▪ បន្តពង្រឹងរចនាសម្ព័ន្ធ ធនធាន និងយន្តការ នៃគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ឱ្យស្របតាមតម្រូវការជាក់ស្តែង។ | មករា - ធ្នូ | - ទីស្តីការគណៈរដ្ឋមន្ត្រី<br>- គ.អ.ទ.ស.<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | - ក្រ.ពាក់ព័ន្ធ<br>- វិស័យឯកជន |
| **វិធានការទី៨ - ពិពិធកម្មផលិតផលទេសចរណ៍មានសក្តានុពលនៅខេត្តសៀមរាប** | | | |
| ▪ លើកទឹកចិត្តក្នុងការទាក់ទាញទេសចរណ៍ម៉ាយ (MICE) ក្នុងខេត្តសៀមរាប តាមរយៈ៖ | | - ក្រសួងទេសចរណ៍<br>- ក្រុមហ៊ុនវិនិយោគ | - គ.អ.ទ.ស.<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - បង្កើតយន្តការសម្របសម្រួលការទាក់ទាញ និងរៀបចំព្រឹត្តិការណ៍ម៉ាយ (MICE) នៅខេត្តសៀមរាប អមជាមួយការផ្តល់ការលើកទឹកចិត្តដល់ភ្ញៀវទេសចរអន្តរជាតិនូវសំបុត្រចូលទស្សនាអង្គរដោយបង់កម្រៃតែពាក់កណ្តាល | មករា - ធ្នូ | | |
| - សិក្សាបង្កើតមជ្ឈមណ្ឌលសន្និបាតនិងពិព័រណ៍សៀមរាប-អង្គរ (Siem Reap-Angkor Convention and Exhibition Center) នៅទីតាំងអាកាសយានដ្ឋានអន្តរជាតិសៀមរាប (ចាស់) ឬទីតាំងសមស្របណាមួយនៅក្នុងក្រុងសៀមរាប។ | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| ▪ រៀបចំព្រឹត្តិការណ៍ទាក់ទាញខ្នាតអន្តរជាតិខេត្តសៀមរាបៈ | | - ក្រសួងទេសចរណ៍<br>- គ.ជ.អ.ក.<br>- អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលខេត្តសៀមរាប | - គ.អ.ទ.ស.<br>- ក្រ.ពាក់ព័ន្ធ<br>- ស.ស.យ.ក.<br>- វិស័យឯកជន |
| - ពិធីបុណ្យឆ្លងឆ្នាំសកល ឆ្នាំ២០២៥ | មករា | | |
| - ព្រឹត្តិការណ៍រត់ប្រណាំងចម្ងាយឆ្ងាយ “Angkor Ultra Trail” | កុម្ភៈ | | |
| - ព្រឹត្តិការណ៍ព្រះអាទិត្យរះចំកណ្តាលកំពូលប្រាសាទអង្គរវត្ត (Equinox) | មីនា / កញ្ញា | | |
| - ព្រឹត្តិការណ៍រត់ប្រណាំងម៉ារ៉ាតុង (Marathon) | សីហា | | |
| - ព្រឹត្តិការណ៍តន្ត្រីរបស់លោក Andrea Bocelli | កក្កដា - សីហា | | |
| - ទិវារត់ប្រណាំងអន្តរជាតិពាក់កណ្តាលម៉ារ៉ាតុង (International Angkor Half Marathon) | ធ្នូ | | |
| - ព្រឹត្តិការណ៍ទេសចរណ៍ខ្នាតអន្តរជាតិផ្សេងៗ។ | មករា - ធ្នូ | | |
| ▪ រៀបចំព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ឆ្នាំ២០២៥ | មេសា | - ស.ស.យ.ក. | - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ / អាជ្ញាធរជាតិអប្សរា<br>- ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តសៀមរាប |
| ▪ កែលម្អផលិតផលដែលមានស្រាប់ រួមទាំងសណ្តាប់ធ្នាប់ សុវត្ថិភាព អនាម័យ និងបរិស្ថាន ព្រមទាំងបង្កើតផលិតផលទាក់ទាញថ្មីៗ (កីឡា ផ្សារទំនើប...) | មករា - ធ្នូ | - ក្រសួងទេសចរណ៍/ គ.ជ.រ.ទ.<br>- រដ្ឋបាលខេត្តសៀមរាប | - ក្រ.ពាក់ព័ន្ធ<br>- វិស័យឯកជន |
| ▪ រៀបចំទស្សនីយភាពអំពី **“គុនល្បុក្កតោ និងគុនខ្មែរចម្រុះ”** សម្រាប់ភ្ញៀវទេសចរ ឱ្យបានជាប្រចាំ ទាំងក្នុងទីក្រុង និងនៅទីលានជល់ដំរី។ | មករា - ធ្នូ | - គ.ជ.អ.ក.<br>- វិស័យឯកជន | - អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលខេត្តសៀមរាប |
| **វិធានការទី៩- កាត់បន្ថយភាពផ្ទុះផ្លាយផ្នែកសេដ្ឋកិច្ចនៅក្នុងខ្សែច្រវាក់តម្លៃទេសចរណ៍** | | | |
| ▪ ពង្រឹងផលិតកម្មក្នុងស្រុក និងការអនុវត្តច្បាប់លើហាងលក់វត្ថុអនុស្សាវរីយ៍ក្លែងក្លាយៈ | | | |

| | | | |
|---|---|---|---|
| - គាំទ្រដល់និរន្តរភាពនៃសិប្បកម្ម និងផលិតករក្នុងស្រុក ទាំងផ្នែកធនធាន និងបច្ចេកទេសផលិត | មករា - ធ្នូ | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងទេសចរណ៍ | - គ.ជ.ភ.១ផ.១<br>- វិស័យឯកជន |
| - ជំរុញការដាក់លក់ផលិតផលក្នុងស្រុក តាមរយៈ ការផ្តល់ស្លាកសញ្ញាទុកចិត្ត (Labelling on Quality Mark and/or Trust Marks) | មករា - មិថុនា | | |
| - ពិនិត្យ ណែនាំ និងអនុវត្តពិន័យអន្តរការណ៍ចំពោះហាងលក់វត្ថុអនុស្សាវរីយ៍ ដែលលក់ផលិតផលក្លែងក្លាយ ដែលដាក់ការផលិតនៅកម្ពុជា | មករា - ធ្នូ | | |
| - ជំរុញសិប្បកម្មផលិតវត្ថុអនុស្សាវរីយ៍ក្នុងស្រុកបម្រើឱ្យភ្ញៀវទេសចរ ក្នុងនោះលើកកម្ពស់ Artisans Angkor និងពង្រឹងការគ្រប់គ្រងហាងវត្ថុអនុស្សាវរីយ៍ អមជាមួយការបង្កើតម៉ាកសញ្ញាសម្រាប់ទទួលស្គាល់ហាងលក់វត្ថុអនុស្សាវរីយនៅខេត្តសៀមរាប។ | មករា - មិថុនា | | |
| ▪ រៀបចំខ្សែក្រវាត់បៃតង (Green Belt) ក្នុងឧស្សាហកម្មទេសចរណ៍ ដើម្បីជំរុញការផ្គត់ផ្គង់កសិផលក្នុងស្រុក ដូចជា បន្លែ ផ្លែឈើ សាច់ និងផ្កា ដល់មូលដ្ឋានអាជីវកម្មទេសចរណ៍ នៅខេត្តសៀមរាប តាមរយៈ ការរៀបចំវេទិកាផ្គូរផ្គងអាជីវកម្ម ឬជំនួបរវាងអ្នកលក់ និងអ្នកទិញ ការលើកកម្ពស់ផលិតផលកសិកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ និងការអភិវឌ្ឍចង្កោមផលិតផលតាមមូលដ្ឋាន ក្រោមគម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច (AIMS) និងគម្រោងអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃ នៅក្នុងឧស្សាហកម្មទេសចរណ៍ខេត្តសៀមរាប។ | មករា - ធ្នូ | - ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តសៀមរាប<br>- គ.អ.ទ.ស.<br>- វិស័យឯកជន |
| **វិធានការទី១០ - បង្កើនសហថាមភាពរវាងតំបន់បេតិកភណ្ឌអង្គរ និងតំបន់ទេសចរណ៍អាទិភាពផ្សេងទៀតក្នុងខេត្តសៀមរាប** | | | |
| ▪ រៀបចំផែនទីទេសចរណ៍សម្រាប់ខេត្តសៀមរាប និងតាមគោលដៅអាទិភាព ដោយបង្ហាញពីខ្សែទស្សនាចរណ៍ ព័ត៌មានគ្រប់ជ្រុងជ្រោយ និងមានភាពទាក់ទាញសម្រាប់ទេសចរជាតិ និងអន្តរជាតិ ដោយរៀបចំជាច្រើនភាសា និងច្រើនជម្រើស ទាំងទម្រង់ជាឯកសារបោះពុម្ព និងទម្រង់ឌីជីថល នូវ៖ | | | |
| - **"ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍វប្បធម៌ បេតិកភណ្ឌ សាសនា និងជំនឿ"** សំដៅដល់ **១)**- ខ្សែទស្សនាចរណ៍បេតិកភណ្ឌពិភពលោក **២)**- ខ្សែទស្សនាចរណ៍បេតិកភណ្ឌប្រាសាទ | មករា - មិថុនា | | |

| | | | |
|---|---|---|---|
| និងតំបន់ធម្មជាតិដ៏ពិសិដ្ឋនៃឧទ្យានជាតិភ្នំគូលែន ដែលមានសកម្មភាពផ្សារភ្ជាប់ជាមួយវត្តអារាមនានា និង/ឬព្រឹត្តិការណ៍សាសនា ដែលឆ្លុះបញ្ចាំងពីសក្ដានុពលនៃទេសចរណ៍សាសនា និងជំនឿ ៣)- ផ្លូវទស្សនាចរណ៍សិក្សាស្វែងយល់និងស្រាវជ្រាវ ដោយផ្សារភ្ជាប់ជាមួយសកម្មភាពទស្សនាតាមទីកន្លែងស្រាវជ្រាវ សារមន្ទីរអរិយធម៌ និងសារមន្ទីរជាច្រើនផ្សេងទៀតក្នុងខេត្តសៀមរាប ដើម្បីពន្យល់អំពីអច្ឆរិយភាពរបស់អង្គរ និងអាចឱ្យភ្ញៀវស្វែងយល់ពីវប្បធម៌ អរិយធម៌ខ្មែរ ប្រវត្តិសាស្ត្រ ជំនឿ និងសាសនា និង ៤)- ផ្លូវទស្សនាចរណ៍ផ្សារភ្ជាប់នឹងឧស្សាហកម្មច្នៃប្រឌិត ដែលផ្សារភ្ជាប់នូវសកម្មភាពទេសចរណ៍នៅនឹងកន្លែង នៃសិប្បកម្ម ការផលិតវត្ថុអនុស្សាវរីយ៍ ការទស្សនាក្បាច់គុនល្បុក្កតោដែលមានអាយុកាលយូរលង់ណាស់មកហើយ ការរៀបចំម្ហូបអាហារខ្មែរ និងចំណីអាហារពិសេសប្រចាំតំបន់ ជាដើម | | | |
| - **“ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍”** សំដៅដល់ **១)-** ខ្សែទស្សនាចរណ៍ទេសចរណ៍ធម្មជាតិ និងអេកូទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា ដូចជា ការទស្សនាភូមិនេសាទ ភូមិបណ្តែតទឹក ដំណើរកម្សាន្តបែបឡើងភ្នំ និងដើរព្រៃ ការជិះទូកកម្សាន្តនៅកំពង់ភ្លុក សួនសត្វស្លាប និងសកម្មភាពកម្សាន្តជាច្រើនផ្សេងទៀត និង **២)-** ខ្សែទស្សនាចរណ៍ផ្សារភ្ជាប់នឹងសកម្មភាពកម្សាន្តដែលគិតគូរអំពីបរិស្ថានខ្ពស់ ដូចជាការចូលរួមដាំដើមឈើក្នុងសួនទេសចរណ៍ ឬទីតាំងនានាដែលមានការរៀបចំសម្រាប់ជាការចងចាំដ៏ល្អមួយដល់ភ្ញៀវទេសចរ និងការទស្សនា និងកម្សាន្តនៅក្នុងទីតាំង ឬតំបន់ទេសចរណ៍គ្មានការប្រើប្រាស់ប្លាស្ទិក ជាដើម។ | មករា - មិថុនា | - ក្រសួងទេសចរណ៍ | - គ.អ.ទ.ស.<br>- អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលខេត្តសៀមរាប<br>- អាជ្ញាធរទន្លេសាប<br>- វិស័យឯកជន |
| - **“ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍ជនបទ និងកសិ-ទេសចរណ៍”** សំដៅដល់ **១)-** ខ្សែទស្សនាចរណ៍នៅតំបន់បឹងទន្លេសាបដែលពោរពេញដោយសត្វត្រីគ្រប់ប្រភេទ និង/ឬការទស្សនាសកម្មភាពនេសាទ របៀបរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរបែបសហគមន៍ទេសចរណ៍ ដែលគួរជាទីចាប់អារម្មណ៍ ប្រកបដោយទេសភាពធម្មជាតិដ៏ស្រស់ត្រកាល អាកាសធាតុ ខ្យល់បរិសុទ្ធ ភាពសម្បូរបែបនៃជីវៈចម្រុះ ដែលអនុញ្ញាតឱ្យភ្ញៀវទេសចរបានស្គាល់អំពីសក្ដានុពល | មករា - មិថុនា | | |

| | | | |
|---|---|---|---|
| នៃភាពជាខ្មែរ និង **២)-** ខ្សែទស្សនាចរណ៍នៅតំបន់បន្ទាយស្រី ដែលផ្សារភ្ជាប់គ្នារវាងប្រាសាទ និងសកម្មភាពទស្សនាទេសភាពកសិកម្មក្នុងតំបន់នោះ ជាអាទិ៍ ការជិះរទេះគោទស្សនាព្រឹត្តិការណ៍ប្រមូលផលកសិកម្ម ការទស្សនាការផលិតស្ករត្នោត និងតម្បាញផ្តៅនៃស្រុកបន្ទាយស្រី ដំណាំស្រែចម្ការ កសិដ្ឋានចិញ្ចឹមត្រីធម្មជាតិ ផ្ទះស្នាក់ស្រុកបន្ទាយស្រី អមដោយការភ្លក់ម្ហូបអាហារខ្មែរ។ល។ | | | |
| - **"ផ្លូវទស្សនាចរណ៍ទេសភាពទីក្រុងបេតិកភណ្ឌប្រវត្តិសាស្ត្រ និងភាពរីករាយ"** សំដៅដល់ **១)-** ខ្សែទស្សនាចរណ៍បេតិកភណ្ឌទីក្រុងប្រវត្តិសាស្ត្ររបស់ខេត្តសៀមរាប ដែលមានអគារបុរាណ និងដើមឈើចាស់ៗជាច្រើនដែលត្រូវបានអភិរក្ស ការទស្សនាសំណង់ស្ថាបត្យកម្មក្នុងវត្តអារាម និងសំណង់ក្នុងសម័យអាណានិគម ព្រះបរមរាជវាំង និងសារមន្ទីរនានា ជាពិសេសការទស្សនា និងកម្សាន្តតាមដងស្ទឹងសៀមរាប ដែលជាស្ទឹងប្រវត្តិសាស្ត្រមួយដ៏សំខាន់សម្រាប់ខេត្តសៀមរាប **២)-** ខ្សែទស្សនាចរណ៍ទេសចរណ៍បែបលម្ហែកាយ ដែលជាការដើរផ្សារទិញទំនិញ វត្ថុអនុស្សាវរីយ៍ ភាពប្រណិតនៃសេវាកម្មទេសចរណ៍ សេវាកម្មកម្សាន្តមនុស្សពេញវ័យ និងភោជនីយដ្ឋានទេសចរណ៍ដែលមានគុណភាព និងបម្រើឱ្យគ្រប់ជាតិសាសន៍ **៣)-** ខ្សែទស្សនាចរណ៍ទេសចរណ៍ម៉ាយ (MICE) រួមមានព្រឹត្តិការណ៍សន្និសីទ កិច្ចប្រជុំនានា សិក្ខាសាលា ឬវេទិកា កម្រិតថ្នាក់ជាតិ តំបន់ និងអន្តរជាតិ អមជាមួយការរៀបចំព្រឹត្តិការណ៍ទាក់ទាញ ដូចជា ព្រឹត្តិការណ៍អង្គរសង្ក្រាន្ត ពិព័រណ៍ មហោស្រពវប្បធម៌អន្តរជាតិ និងការប្រគុំតន្ត្រីធំៗ ដែលមានបញ្ចូលលក្ខណៈសិល្បៈ និងតន្ត្រីខ្មែរ ជាដើម។ | មករា - មិថុនា | | |
| - **"ផ្លូវទស្សនាចរណ៍ទៅកាន់ទេសចរណ៍វ័យចំណាស់ ទេសចរណ៍សុខភាព និងទេសចរណ៍ផ្ទះទី២"** សំដៅដល់ **១)-** ខ្សែទស្សនាចរណ៍សម្រាប់ទេសចរវ័យចំណាស់ និងទេសចរណ៍សុខភាពដែលផ្សារភ្ជាប់នឹងសកម្មភាពកម្សាន្ត និងលម្ហែកាយ ដូចជា ការសម្រាកលំហែកាយនៅផ្ទះស្នាក់ធម្មជាតិ ការទទួលនូវសេវាកម្មស្ប៉ា និងម៉ាស្សាស្របតាមស្តង់ដាជាតិ និងអាស៊ាន ការធ្វើសមាធិនៅទីតាំងសមរម្យ ការបរិភោគម្ហូបអាហារដែលគ្មានជាតិគីមី ការទិញទំនិញសុខភាព និងសកម្មភាពកម្សាន្ត | មករា - មិថុនា | | |

| | | | |
|---|---|---|---|
| ផ្សេងៗទៀត ២)- ខ្សែទស្សនាចរណ៍ទេសចរណ៍សុខភាព ជាអាទិ៍ ការពិនិត្យសុខភាពនៅមន្ទីរពេទ្យ វេជ្ជសាស្ត្រ ឬគ្លីនិក ការទិញផលិតផលថែរក្សាសម្រស់ សេវាកម្មទន្តសាស្ត្រ ជាដើម និង ៣)- ខ្សែទស្សនាចរណ៍បែបកីឡាដោយផ្សារភ្ជាប់ទៅនឹងការទស្សនាព្រឹត្តិការណ៍កីឡាជាតិ និងអន្តរជាតិធំៗ អមជាមួយការរៀបចំសកម្មភាពកីឡាទេសចរណ៍នៅក្នុងខេត្តសៀមរាប ដូចជា ជិះកង់កម្សាន្ត គយគន់ទេសភាព រត់ប្រណាំងម៉ារ៉ាតុង (កម្រិតស្រាល) វាយកូនគោល ជាដើម ដើម្បីសុខភាព។ | | | |
| ▪ សហការជាមួយការីទេសចរណ៍ក្នុងការបញ្ចូលកញ្ចប់ទស្សនកិច្ចដោយមានតម្លៃសមរម្យសម្រាប់ភ្ញៀវទេសចរ ដែលមកទស្សនាខេត្តសៀមរាបនូវផ្លូវទស្សនាចរណ៍ខាងលើ | មករា - ធ្នូ | - ក្រសួងទេសចរណ៍ | - គ.អ.ទ.ស.<br>- Sub-DMO<br>- វិស័យឯកជន |
| ▪ រៀបចំប្រព័ន្ធទេសចរណ៍ធ្វើដំណើរដោយខ្លួនឯង (Self-driving tourists and FIT) សម្រាប់ទេសចរណ៍នៅខេត្តសៀមរាប។ | មករា - មិថុនា | - គ.អ.ទ.ស. | - ក្រសួងទេសចរណ៍<br>- Sub-DMO |
| **វិធានការទី១១ - បង្កើនសហថាមភាពរវាងខេត្តសៀមរាប និងគោលដៅអាទិភាពរបស់កម្ពុជា** | | | |
| ▪ បង្កើនសហថាមភាពផ្នែកទេសចរណ៍រវាងរាជធានីភ្នំពេញ - ខេត្តសៀមរាប | | - ក្រសួងទេសចរណ៍ | - គ.អ.ទ.ស.<br>- អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលរាជធានីភ្នំពេញ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| - ជំរុញការតភ្ជាប់ជើងហោះហើរ (Flight) ឱ្យមានតម្លៃសមរម្យ | មករា - ធ្នូ | | |
| - រៀបចំរថយន្តទេសចរណ៍ (bus) ដែលធានាសុវត្ថិភាព និងគុណភាព | មករា - មេសា | | |
| - រៀបចំសៀគ្វីទេសចរណ៍បេតិកភណ្ឌផ្សារភ្ជាប់នឹងទេសចរណ៍ទីក្រុង។ | មករា - មិថុនា | | |
| ▪ បង្កើនសហថាមភាពផ្នែកទេសចរណ៍រវាងខេត្តព្រះសីហនុ - ខេត្តសៀមរាប | | - ក្រសួងទេសចរណ៍ | - គ.អ.ទ.ស.<br>- អាជ្ញា[illegible]<br>- រដ្ឋ[illegible]ខេត្តសៀមរាប<br>- រដ្ឋ[illegible]ខេ[illegible]<br>- វិ[illegible]ជន |
| - ជំរុញការតភ្ជាប់ជើងហោះហើរ (Flight) ឱ្យមានតម្លៃសមរម្យ | មករា - ធ្នូ | | |
| - រៀបចំរថយន្តទេសចរណ៍ (bus) ដែលធានាសុវត្ថិភាព និងគុណភាព | មករា - មេសា | | |
| - រៀបចំសៀគ្វីទេសចរណ៍បេតិកភណ្ឌផ្សារភ្ជាប់នឹងទេសចរណ៍សមុទ្រ។ | មករា - មិថុនា | | |

| | | | |
|---|---|---|---|
| ▪ បង្កើនសហថាមភាពផ្នែកទេសចរណ៍រវាងខេត្តសៀមរាប និងតំបន់ជុំវិញ | | - គ.អ.ទ.ស. | - ក្រសួងទេសចរណ៍<br>- អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលខេត្តសៀមរាប<br>- រដ្ឋបាលខេត្តពាក់ព័ន្ធ<br>- វិស័យឯកជន |
| - បង្កើតសៀគ្វីទេសចរណ៍បេតិកភណ្ឌទេសចរណ៍ពិភពលោក (ព្រះវិហារ - សៀមរាប - កំពង់ធំ) | មករា - មិថុនា | | |
| - បង្កើតសៀគ្វីទេសចរណ៍ខេត្តសៀមរាបភ្ជាប់នឹងបណ្តាខេត្តជុំវិញ។ | មិថុនា - ធ្នូ | | |
| ▪ បង្កើតបណ្ណទស្សនាសៀមរាប (Siem Reap Pass)។ | មករា - កក្កដា | - គ.អ.ទ.ស. | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តសៀមរាប<br>- Sub-DMO<br>- គ្រឹះស្ថានអង្គរ<br>- វិស័យឯកជន |
| **វិធានការទី១២ - ពង្រឹងសេវាកម្ម និងឧស្សាហកម្មទេសចរណ៍ស្របតាមតម្រូវការភ្ញៀវទេសចរគ្រប់ប្រភេទ** | | | |
| ▪ សិក្សាធ្វើទំនើបកម្ម និងឌីជីថលូបនីយកម្មគោលដៅទេសចរណ៍ និងអាជីវកម្មទេសចរណ៍ | | - ក្រសួងទេសចរណ៍ | - គ.ស.ធ.ឌ.<br>- គ.អ.ទ.ស.<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ធនាគារជាតិនៃកម្ពុជា<br>- រដ្ឋបាលខេត្តសៀមរាប<br>- Sub-DMO<br>- គ្រឹះស្ថានពាក់ព័ន្ធ<br>- វិស័យឯកជន |
| - កែលម្អបទពិសោធទេសចរណ៍ និងជំរុញការប្រើប្រាស់បច្ចេកវិទ្យា នៅក្នុងការគ្រប់គ្រងគោលដៅទេសចរណ៍ គំរូអាជីវកម្មទេសចរណ៍ និងអាជីវកម្មក្នុងវិស័យគាំទ្រ ដើម្បីបង្កើនភាពទាក់ទាញរបស់ផលិតផល និងសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប | មករា - ធ្នូ | | |
| - បង្កើនការប្រើប្រាស់ប្រព័ន្ធទូទាត់ប្រាក់ជាឌីជីថលឱ្យបានទូលំទូលាយ | មករា - ធ្នូ | | |
| - ពង្រឹងសមត្ថភាពមគ្គុទ្ទេសក៍ទេសចរណ៍ និងការផ្តល់សេវាកម្មប្រកបដោយភាពកក់ក្តៅនិងវិជ្ជាជីវៈ។ | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| ▪ កម្មវិធីអភិវឌ្ឍន៍មូលធនមនុស្សដើម្បីភាពធន់និងចីរភាព | មករា - ធ្នូ | - គ.អ.ទ.ស.<br>- ក្រសួងទេសចរណ៍ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន<br>- ដៃគូអភិវឌ្ឍ |
| ▪ ពង្រឹងភាពធន់នៃឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប តាមរយៈ បន្តការលើកទឹកចិត្តពន្ធដារចំពោះសហគ្រាសក្នុងវិស័យទេសចរណ៍នៅខេត្តសៀមរាប និងវិធានការអន្តរាគមន៍ផ្នែកពន្ធដារនានា ដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ឆ្នាំ២០២៥។ | មិថុនា - ធ្នូ | - ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | - ក្រសួងទេសចរណ៍<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| **វិធានការទី១៣ - កាត់បន្ថយគម្លាតនៃដំណើរកម្សាន្តទេសចរណ៍រវាងរដូវភ្ញៀវតិច/រដូវកាលបៃតង (Green Season) និងរដូវភ្ញៀវច្រើន** | | | |
| ▪ ជំរុញការទាក់ទាញទីផ្សារទេសចរណ៍ដែលច្រើនមកទស្សនាខេត្តសៀមរាបនៅរដូវកាលភ្ញៀវតិច/រដូវកាលបៃតង ជាអាទិ៍៖ ទីផ្សារក្នុងតំបន់ ទីផ្សារអារ៉ាប់... | មករា - តុលា | - ក្រសួងទេសចរណ៍ | - ក.ផ.ផ.<br>- វិស័យឯកជន |
| ▪ កំណត់ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំរបស់ខេត្តសៀមរាប និងទាក់ទាញការរៀបចំព្រឹត្តិការណ៍អន្តរជាតិ និងព្រឹត្តិការណ៍ថ្នាក់ជាតិ ព្រមទាំងព្រឹត្តិការណ៍នៅតាមមូលដ្ឋានក្រុង ស្រុក ឃុំ/សង្កាត់ ឱ្យមានក្នុងកំឡុងពេលរដូវកាលភ្ញៀវតិច/រដូវកាលបៃតង | មករា - កុម្ភៈ | -ក្រសួងទេសចរណ៍<br>-រដ្ឋបាលខេត្តសៀមរាប | -ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ<br>-ក្រ.ពាក់ព័ន្ធ<br>-វិស័យឯកជន |
| ▪ ដាក់ចេញយុទ្ធនាការបញ្ចុះថ្លៃលើគ្រប់សេវាទាំងអស់នៅរដូវកាលភ្ញៀវតិច ដូចជាបញ្ចុះតម្លៃលើសេវាកម្មដឹកជញ្ជូន មគ្គុទ្ទេសក៍ សំបុត្រចូលទស្សនា សេវាស្នាក់នៅ និងសេវាកម្សាន្តផ្សេងៗ ដោយផ្នែករដ្ឋនិងឯកជនសហការបញ្ចុះតម្លៃព្រមគ្នាតែម្តង តាមរយៈការរៀបចំ "**កិច្ចសន្យាគោលដៅ**" អនុវត្តយុទ្ធនាការ "**ចុះថ្លៃ**" នៅរដូវកាលភ្ញៀវតិច/រដូវកាលបៃតង | មករា - មីនា | -ក្រសួងទេសចរណ៍<br>-គ្រឹះស្ថានអង្គរ | -គ.អ.ទ.ស.<br>-រដ្ឋបាលខេត្តសៀមរាប<br>-ក្រ.ពាក់ព័ន្ធ<br>-វិស័យឯកជន |

| | | | |
|---|---|---|---|
| ▪ សិក្សាផ្តល់ការលើកលែងកម្រៃទិដ្ឋាការទេសចរណ៍នៅក្នុងអំឡុងពេលរដូវកាលភ្ញៀវតិច/រដូវកាលបៃតង។ | មករា - កុម្ភៈ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>-ក្រសួងមហាផ្ទៃ<br>-ក្រសួងទេសចរណ៍/ក.ជ.ជ. |
| [illegible] | | | |
| **វិធានការទី១៤- បង្កើនការចងចាំល្អ ដោយផ្តល់បទពិសោធល្អដល់ភ្ញៀវទេសចរ** | | | |
| ▪ ដាក់ចេញយុទ្ធនាការ "**អង្គរ : គ្មានប្លាស្ទិក**" "**តូលេន : គ្មានប្លាស្ទិក**" " **ទន្លេសាប : គ្មានប្លាស្ទិក**" ត្រឹមឆ្នាំ២០៣០ សម្រាប់គោលដៅទេសចរណ៍សៀមរាប-អង្គរ | មករា - ធ្នូ | - ក្រសួងបរិស្ថាន | - អាជ្ញាធរជាតិអប្សរា<br>- ក្រសួងទេសចរណ៍ / គ.ជ.វ.ទ.<br>- រដ្ឋបាលខេត្តសៀមរាប<br>- អាជ្ញាធរទន្លេសាប<br>- Sub-DMO<br>- វិស័យឯកជន<br>- សហគមន៍ |
| ▪ ពង្រឹងចលនាប្រឡងប្រណាំង "**ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ បដិសណ្ឋារកិច្ចល្អ**" និងជំរុញបដិសណ្ឋារកិច្ចល្អនៅតាមគ្រប់គោលដៅនិងសេវាកម្មទេសចរណ៍ | | - ក្រសួងទេសចរណ៍/ គ.ជ.វ.ទ. | - អ.អ. / ក្រសួងមហាផ្ទៃ<br>- អាជ្ញាធរជាតិអប្សរា<br>- វិស័យឯកជន<br>- សហគមន៍<br>- រដ្ឋបាលខេត្តសៀមរាប<br>- Sub-DMO |
| - បង្កើនគុណភាពបដិសណ្ឋារកិច្ច ផ្តល់ដោយមន្ត្រីអន្តោប្រវេសន៍ | មករា - ធ្នូ | | |
| - បង្កើនគុណភាពបដិសណ្ឋារកិច្ច និងផ្តល់ភាពជឿជាក់ដល់ភ្ញៀវទេសចរ ដោយអ្នកបើកបរ និងសេវាដឹកជញ្ជូនទេសចរណ៍ អ្នកបើកកាណូតនៅបឹងទន្លេសាប មន្ត្រីត្រួតពិនិត្យសំបុត្រចូលទស្សនាតាមប្រាសាទ អ្នកបម្រើសេវាកម្មនៅគ្រប់មូលដ្ឋានអាជីវកម្មទេសចរណ៍ | មករា - ធ្នូ | | |
| - លើកទឹកចិត្តឱ្យមានជម្រើសមធ្យោបាយដឹកជញ្ជូនច្រើនសម្រាប់ទេសចរ | មករា - មិថុនា | | |
| - ពង្រឹងគុណភាព អនាម័យ និងការផ្តល់សេវាកម្មល្អ និងបដិសណ្ឋារកិច្ចល្អ។ | មករា - ធ្នូ | | |



ម្ម

| | | | |
|---|---|---|---|
| **វិធានការទី១៥ - ពង្រឹងសន្តិសុខនិងសណ្តាប់ធ្នាប់** | | | |
| ▪ ពង្រឹងសន្តិសុខ សុវត្ថិភាព និងភាពកក់ក្តៅដល់ភ្ញៀវទេសចរនៅតាមគោលដៅទេសចរណ៍ ក្នុងនោះត្រូវបង្កើតប្រព័ន្ធទូរសព្ទទំនាក់ទំនង Hotline ការពង្រឹងសមត្ថភាពសង្គ្រោះ ការបំពាក់កាមេរ៉ាសុវត្ថិភាពនៅទីតាំងសំខាន់ៗ | មករា - ធ្នូ | - ក្រសួងមហាផ្ទៃ / ន.ប.ជ.ក. | - រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| ▪ ពង្រឹងសណ្តាប់ធ្នាប់ក្នុងក្រុងសៀមរាប ពិសេសពង្រឹងការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនទេសចរណ៍គ្រប់ប្រភេទនៅខេត្តសៀមរាប។ | មករា - ធ្នូ | - ក្រសួងមហាផ្ទៃ / ន.ប.ជ.ក. | - រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| **វិធានការទី១៦ - បង្កើនការទទួលខុសត្រូវរបស់ប្រតិបត្តិករទេសចរណ៍នៅខេត្តសៀមរាប** | | | |
| ▪ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា ដើម្បីពង្រឹងអនុលោមភាព និងគុណភាពឧស្សាហកម្មទេសចរណ៍នៅខេត្តសៀមរាប ជាអាទិ៍ ការលុបបំបាត់កញ្ចប់ទេសចរណ៍ "ថ្លៃសូន្យ" (Zero-Cost Tour) ការឆបោកភ្ញៀវទេសចរ បទល្មើស និងឧក្រិដ្ឋកម្មនានា ក្នុងវិស័យទេសចរណ៍ | មករា - ធ្នូ | - ក្រសួងទេសចរណ៍ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងមហាផ្ទៃ / ន.ប.ជ.ក.<br>- រដ្ឋបាលខេត្តសៀមរាប<br>- ក្រ.ពាក់ព័ន្ធ<br>- វិស័យឯកជន |
| ▪ ពង្រឹងគុណភាពផលិតផល និងសេវាកម្មទេសចរណ៍នៅខេត្តសៀមរាប តាមរយៈការប្រឡងប្រណាំងអាជីវកម្មឆ្នើម ដោយប្រើប្រាស់ប្រព័ន្ធចំណាត់ថ្នាក់ និងស្តង់ដាគុណភាពទេសចរណ៍ដាក់ចេញដោយថ្នាក់ជាតិនិងអាស៊ាន | មករា - ធ្នូ | - ក្រសួងទេសចរណ៍ | - រដ្ឋបាលខេត្តសៀមរាប<br>- Sub-DMO<br>- វិស័យឯកជន |
| ▪ រៀបចំនិងជំរុញការអនុវត្តក្រមសីលធម៌ និងក្រមប្រតិបត្តិវិជ្ជាជីវៈ សម្រាប់សេវាកម្មទេសចរណ៍ | មករា - ធ្នូ | - ក្រសួងទេសចរណ៍ | - រដ្ឋបាលខេត្តសៀមរាប<br>- Sub-DMO<br>- វិស័យឯកជន |

| | | | |
|---|---|---|---|
| ▪ ពង្រឹងការគ្រប់គ្រងសេវាកម្រៃជើងសា (Commission) និងសេវាកម្រៃបន្ថែម (Service Charge) នៅក្នុងវិស័យទេសចរណ៍។ | មករា - ធ្នូ | - រដ្ឋបាលខេត្តសៀមរាប | - ក្រសួងទេសចរណ៍<br>- ក្រសួងពាណិជ្ជកម្ម<br>- វិស័យឯកជន |
| **វិធានការទី១៧ - អង្កេតស្ដីពីភាពពេញចិត្តរបស់ភ្ញៀវទេសចរ** | | | |
| ▪ រៀបចំអង្កេត និងសិក្សាវាយតម្លៃពីភាពពេញចិត្តរបស់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ នៅតាមគោលដៅអាទិភាព ដើម្បីបានជាមូលដ្ឋានក្នុងការដាក់ចេញនូវយុទ្ធសាស្ត្រទាក់ទាញ បង្កើនគុណភាពបដិសណ្ឋារកិច្ច និងការរៀបចំសម្បទាសមស្រប សំដៅទាក់ទាញឱ្យភ្ញៀវទេសចរមកម្ដងទៀត | មករា - ធ្នូ | - គ.អ.ទ.ស. | - ក្រសួងទេសចរណ៍<br>- អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលខេត្តសៀមរាប<br>- Sub-DMO<br>- វិស័យឯកជន |
| ▪ រៀបចំការវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តគម្រោងសំខាន់ៗ ពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តសៀមរាបតាមការចាំបាច់។ | មករា - ធ្នូ | - គ.អ.ទ.ស. | - ក្រ.ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប |
| **ចង្កោមទី២ - ទាក់ទាញភ្ញៀវទេសចរក្នុងស្រុក[5] មកទស្សនាខេត្តសៀមរាប** | | | |
| **វិធានការគន្លឹះទី៦ - បង្កើនភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរជាតិមកទស្សនាខេត្តសៀមរាប** | | | |
| **វិធានការទី១៨ - រៀបចំ និងសម្រួលឱ្យមានការធ្វើចលនាទេសចរណ៍ផ្ទៃក្នុងទៅកាន់ខេត្តសៀមរាបឱ្យបានកាន់តែច្រើន** | | | |
| ▪ សហការជាមួយការីទេសចរណ៍ និងទីភ្នាក់ងារទេសចរណ៍ក្នុងស្រុក រៀបចំកញ្ចប់ទស្សនកិច្ចក្នុងស្រុកដែលមានថ្លៃសមរម្យ ប្លែកៗ ចម្រុះ និងប្រកបដោយគុណភាព សម្រាប់ភ្ញៀវទេសចរក្នុងស្រុក | មករា - មិថុនា | - ក្រសួងទេសចរណ៍ | - រដ្ឋបាលខេត្តសៀមរាប<br>- អាជ្ញាធរជាតិអប្សរា<br>- Sub-DMO<br>- វិស័យឯកជន |

[5] ភ្ញៀវទេសចរក្នុងស្រុក សំដៅដល់ភ្ញៀវទេសចរជាតិ និងភ្ញៀវបរទេសផ្ទៃក្នុងដែលស្នាក់នៅកម្ពុជា។

| | | | |
|---|---|---|---|
| ▪ បង្កើនសកម្មភាពកម្សាន្តសម្រាប់ទេសចរជាលក្ខណៈគ្រួសារ ដែលអាចបំពេញតម្រូវការបានទាំងឪពុក ម្តាយ កូន និងក្មេងតូចៗ ព្រោះថាភ្ញៀវទេសចរប្រភេទនេះយកចិត្តទុកដាក់ខ្ពស់ចំពោះភាពរីករាយរបស់សមាជិកគ្រួសារទាំងមូលក្នុងអំឡុងពេលដំណើរកម្សាន្ត | កុម្ភៈ - កញ្ញា | - ក្រសួងទេសចរណ៍ | - រដ្ឋបាលខេត្តសៀមរាប<br>- អាជ្ញាធរជាតិអប្សរា<br>- Sub-DMO<br>- វិស័យឯកជន |
| ▪ បញ្ចូលកម្មវិធីទស្សនកិច្ចសិក្សាសម្រាប់សិស្ស-និស្សិត និងគ្រូបង្រៀននៅតាមគ្រឹះស្ថានបណ្តុះបណ្តាលនានាទៅតំបន់បេតិកភណ្ឌអង្គរ ខេត្តសៀមរាប | មករា - ធ្នូ | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍ | - វិស័យឯកជន<br>- អាជ្ញាធរជាតិអប្សរា<br>- រដ្ឋបាលខេត្តសៀមរាប<br>- គ្រឹះស្ថានបណ្តុះបណ្តាល |
| ▪ បញ្ចូលកម្មវិធីទស្សនកិច្ចសម្រាប់មន្ត្រីរាជការរបស់ក្រសួង-ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិទៅតំបន់បេតិកភណ្ឌអង្គរ ខេត្តសៀមរាប | មករា - ធ្នូ | - ក្រ.ពាក់ព័ន្ធ<br>- ក្រសួងទេសចរណ៍ | - រដ្ឋបាលខេត្តសៀមរាប<br>- រដ្ឋបាលថ្នាក់ក្រោមជាតិ |
| ▪ បញ្ចូលកម្មវិធីទស្សនកិច្ចសម្រាប់បុគ្គលិកក្នុងវិស័យឯកជន ទៅតំបន់បេតិកភណ្ឌអង្គរ ខេត្តសៀមរាប | មករា - ធ្នូ | - ក្រសួងទេសចរណ៍<br>- វិស័យឯកជន | - សភាពាណិជ្ជកម្ម<br>- រដ្ឋបាលខេត្តសៀមរាប |
| ▪ រៀបចំនិងជំរុញការប្រើប្រាស់ **"បណ្ណដំណើរកម្សាន្ត"** ដែលមានតម្លៃសមរម្យសម្រាប់ភ្ញៀវទេសចរជាតិពិសេសសម្រាប់មន្ត្រីរាជការ កងកម្លាំងសមត្ថកិច្ច គ្រូបង្រៀន កម្មករ-កម្មការិនី | មករា - មិថុនា | - ក្រសួងទេសចរណ៍ | - វិស័យឯកជន<br>- Sub-DMO |
| ▪ បន្តពិនិត្យលើការបន្ធូរបន្ថយកម្រៃសម្រាប់សេវាកម្មទេសចរណ៍នៅតាមគោលដៅទេសចរណ៍សំខាន់ៗក្នុងខេត្តសៀមរាបឱ្យមានតម្លៃសមរម្យសម្រាប់ភ្ញៀវទេសចរជាតិ (ឧទា. តម្លៃជិះទូកនៅចុងឃ្នៀស[6]...) | មករា - ធ្នូ | -ក្រសួងទេសចរណ៍<br>-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ/គ្រឹះស្ថានអង្គរ<br>-រដ្ឋបាលខេត្តសៀមរាប | -ក្រ.ពាក់ព័ន្ធ<br>-វិស័យឯកជន<br>-សហគមន៍ |
| ▪ បន្តជំរុញគម្រោងសាងសង់ផ្លូវល្បឿនលឿនពីរាជធានីភ្នំពេញ-ខេត្តសៀមរាប។ | មករា - ធ្នូ | - ក្រសួងសាធារណការ និងដឹកជញ្ជូន | - ក្រុមហ៊ុនសាងសង់ផ្លូវល្បឿនលឿនចិន (CRBC)<br>- រដ្ឋបាលខេត្តសៀមរាប |

[6] គ្រឹះស្ថានអង្គរបានកែសម្រួលការងារនេះ ក្រោយទទួលបានការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**។

| វិធានការទី១៩- ដាក់ចេញយុទ្ធសាស្ត្រលើកកម្ពស់ការយល់ដឹងជាសាធារណៈ | | | |
|---|---|---|---|
| ▪ ពង្រឹងយុទ្ធនាការ "**ទស្សនាស្រុកយើង**" ក្រោមស្ទាវតី "**ស្រលាញ់ជាតិ ត្រូវស្គាល់ទឹកដី**" និង "**ទេសចរណ៍ផ្សារភ្ជាប់ទឹកដី និងធម្មជាតិ**" | មករា - ធ្នូ | - ក្រសួងទេសចរណ៍ | - ក. ផ. ផ.<br>- ក្រ. ពាក់ព័ន្ធ<br>- វិស័យឯកជន |
| ▪ បង្កើតនូវបទសម្ភាសន៍ជាមួយបុគ្គលសំខាន់ៗនៅក្នុងវិស័យទេសចរណ៍ ដូចជា ថ្នាក់ដឹកនាំ មន្ត្រី អ្នកជំនាញ ប្រតិបត្តិករទេសចរណ៍ និងភាគីពាក់ព័ន្ធ មកពីវិស័យរដ្ឋនិងឯកជន ដែលមានភាពជោគជ័យ នៅក្នុងកម្មវិធីទូរទស្សន៍និងវិទ្យុល្បីៗជាប្រចាំ ដើម្បីលើកទឹកចិត្តឱ្យប្រជាពលរដ្ឋស្វែងយល់និងចូលរួមចំណែកនៅក្នុងសកម្មភាពអភិវឌ្ឍន៍វិស័យទេសចរណ៍ | មករា - ធ្នូ | - ក្រសួងទេសចរណ៍ | - ក. ផ. ផ.<br>- ក្រសួងព័ត៌មាន<br>- វិស័យឯកជន |
| ▪ បំផុសចលនាផ្សព្វផ្សាយ តាមរយៈប្រជាពលរដ្ឋម្ចាស់ស្រុក និងម្ចាស់អាជីវកម្ម ដោយ "**អ្នកស្រុកណា ផ្សាយពីស្រុកនោះ**" និង "**អាជីពណា ផ្សាយពីអាជីពនោះ**" ស្របតាមទស្សនាទាន "**ទេសចរណ៍ដើម្បីទាំងអស់គ្នា ទាំងអស់គ្នាដើម្បីទេសចរណ៍**" និង "**ម្នាក់ៗ ជាអ្នកផ្សព្វផ្សាយទេសចរណ៍កម្ពុជាម្នាក់**" ដែលជាការផ្សព្វផ្សាយបង្ហោះដោយខ្លួនឯងលើបណ្ដាញសង្គម ដូចជា ការថតពីសកម្មភាពកម្សាន្តទេសភាពរបស់ទីតាំង រូបភាព និងវីដេអូ អមជាមួយការពិពណ៌នាខ្លីៗ | មករា - ធ្នូ | - ក្រសួងទេសចរណ៍ | - រដ្ឋបាលខេត្តសៀមរាប<br>- អ្នកសារព័ត៌មាន<br>- ប្រជាពលរដ្ឋ<br>- វិស័យឯកជន |
| ▪ ការរំលេចសាច់រឿង (Feature Stories) ដើម្បីបង្កើនចំណាប់អារម្មណ៍របស់សាធារណជននៅក្នុងការធ្វើដំណើរកម្សាន្តផ្ទៃក្នុង ដោយត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា៖ | | - ក្រសួងទេសចរណ៍ | - ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា<br>- ក្រសួងព័ត៌មាន<br>- ក្រ. ពាក់ព័ន្ធ<br>- វិស័យឯកជន |
| - លើកទឹកចិត្តប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក ឱ្យមានការសរសេរជាអត្ថបទរំលេចអំពីប្រភេទទេសចរណ៍ដែលទាក់ទាញចំណាប់អារម្មណ៍របស់អ្នកអាន | មករា - មិថុនា | | |
| - ជំរុញការផលិតខ្សែភាពយន្តដែលបង្ហាញពីគោលដៅទេសចរណ៍អាទិភាពសំខាន់ៗក្នុងខេត្តសៀមរាប | មករា - ធ្នូ | | |

| | | | |
|---|---|---|---|
| - ផលិតវីដេអូអំពីគោលដៅសក្តានុពលទេសចរណ៍ក្នុងខេត្តសៀមរាប និងចម្រៀងទេសចរណ៍ ដើម្បីចាក់ផ្សាយតាមបណ្តាញស្ថានីយទូរទស្សន៍ និងប្រព័ន្ធបណ្តាញសង្គមនានា | មេសា - សីហា | | - ក្លឹបអ្នកកាសែតកម្ពុជា<br>- បុគ្គលល្បីៗ<br>- សិល្បករ សិល្បការិនី<br>- ពិធីករ ពិធីការិនី<br>- អ្នកថតរូប |
| - ជំរុញការផ្សព្វផ្សាយ ការផលិតរូបភាព វីដេអូ និងមាតិកាទេសចរណ៍ ការអប់រំ និងបញ្ជ្រាបការយល់ដឹងជាសាធារណៈអំពីវិស័យទេសចរណ៍ តាមរយៈបុគ្គលដែលមានឥទ្ធិពល (Influencers) និងអ្នកផលិតរូបភាព និងវីដេអូជំនាញ នៅលើប្រព័ន្ធផ្សព្វផ្សាយបណ្តាញសង្គម (YouTube, Facebook, Tiktok, Instagram, X ...) និងប្រព័ន្ធផ្សព្វផ្សាយនានា។ | មករា - ធ្នូ | | |
| **វិធានការទី២០ - លើកទឹកចិត្តការរៀបចំកម្មវិធីផ្សេងៗ ដូចជាកិច្ចប្រជុំនិងសិក្ខាសាលានៅខេត្តសៀមរាបនារដូវភ្ញៀវតិច** | | | |
| ▪ រៀបចំព្រឹត្តិការណ៍និងកម្មវិធីកម្សាន្តឱ្យបានច្រើននៅរដូវកាលភ្ញៀវតិច | មិថុនា - កញ្ញា | - ក្រសួងទេសចរណ៍ | - ក្រ. ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| ▪ ទាក់ទាញការរៀបចំកិច្ចប្រជុំ និងសិក្ខាសាលានានា នៅខេត្តសៀមរាប ជាពិសេសនារដូវភ្ញៀវតិច តាមរយៈកិច្ចសហការជាមួយវិស័យឯកជនក្នុងការបង្កើតកម្មវិធីផ្តល់ជូនក្នុងតម្លៃពិសេស។ | មិថុនា - កញ្ញា | - ក្រសួងទេសចរណ៍<br>- គ.អ.ទ.ស. | - ក្រ. ពាក់ព័ន្ធ<br>- រដ្ឋបាលខេត្តសៀមរាប<br>- វិស័យឯកជន |
| **វិធានការទី២១ - បន្តបង្កើនភាពទាក់ទាញតាមរយៈការរៀបចំព្រឹត្តិការណ៍ទេសចរណ៍ធំៗប្រចាំឆ្នាំក្នុងខេត្តសៀមរាបឱ្យបានច្រើន** | | | |
| ▪ ក្រៅពីព្រឹត្តិការណ៍ទេសចរណ៍អន្តរជាតិ (ដូចមានចង្អុលក្នុងវិធានការទី៨) ត្រូវរៀបចំព្រឹត្តិការណ៍ទេសចរណ៍ប្រចាំឆ្នាំផ្សេងៗទៀតក្នុងខេត្តសៀមរាបឱ្យបានច្រើន ជាអាទិ៍៖ | | - ក្រសួងទេសចរណ៍<br>- វិស័យឯកជន | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ/អាជ្ញាធរជាតិអប្សរា<br>- ក្រសួងធម្មការនិងសាសនា |
| - ព្រឹត្តិការណ៍ទេសចរណ៍ បុណ្យទាន ប្រពៃណី ពិធីបុណ្យ និងព្រឹត្តិការណ៍សាសនាផ្សេងៗ (ដូចជាបដិបត្តិសមាធិ និងពិធីរាប់បាត្រព្រះសង្ឃ ជាដើម) | មករា - ធ្នូ | | |
| - ព្រឹត្តិការណ៍កីឡា ពិសេសព្រឹត្តិការណ៍កម្រិតថ្នាក់ជាតិ ដូចជា ព្រឹត្តិការណ៍ជិះកង់ និងរត់ម៉ារ៉ាតុង | មករា - ធ្នូ | | |
| - ទិវាអន្តរជាតិកីឡាយ៉ូហ្គា | មិថុនា | | |

| | | | |
|---|---|---|---|
| - ព្រឹត្តិការណ៍ **"ស្នាមញញឹមនៃកម្ពុជា"** | មករា - ធ្នូ | | - រដ្ឋបាលខេត្តសៀមរាប<br>- គ.ជ.ប.អ.<br>- គ.ជ.អ.ក.<br>- ស.ស.យ.ក. |
| - សិក្សាបង្កើតកម្មវិធី ឬបុណ្យថ្មីៗផ្សារភ្ជាប់នឹងទេសចរណ៍ប្រចាំឆ្នាំសម្រាប់ខេត្តសៀមរាប ដូចជា បុណ្យតន្ត្រី ពិធីបុណ្យពន្លឺអង្គរ។ល។ | មករា - ធ្នូ | | |
| **វិធានការទី២២ - ទាក់ទាញភ្ញៀវទេសចរជាប្រជាពលរដ្ឋខ្មែររស់នៅក្រៅប្រទេស មកទស្សនាខេត្តសៀមរាប** | | | |
| ▪ ពង្រឹង និងបង្កើនការផ្សព្វផ្សាយទាក់ទាញប្រជាពលរដ្ឋខ្មែរ និងសហគមន៍ខ្មែរដែលរស់នៅក្រៅប្រទេស តាមរយៈ៖ | | - ក្រសួងទេសចរណ៍ | - ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ / ស្ថានតំណាងកម្ពុជានៅបរទេស<br>- យុវជនគណបក្សប្រជាជនកម្ពុជានៅក្រៅប្រទេស (CPP)<br>- ស.ស.យ.ក. |
| - បំផុស និងលើកទឹកចិត្តឱ្យមកទស្សនាទឹកដីអង្គរដែលជាដែនដីមាតុភូមិ ក្រោមយុទ្ធនាការផ្សព្វផ្សាយ **"ស្រឡាញ់ជាតិ ត្រូវស្គាល់ទឹកដី"** | មករា - ធ្នូ | | |
| - ជំរុញឱ្យមានការចូលរួមផ្សព្វផ្សាយអំពីរូបភាពវិជ្ជមានរបស់ទឹកដីកំណើតខ្លួន និងសក្តានុពលទេសចរណ៍របស់ខេត្តសៀមរាប តាមរយៈការដាក់ចេញនូវយន្តការលើកទឹកចិត្តនានាដល់ប្រជាពលរដ្ឋខ្មែរ និងសហគមន៍ខ្មែរដែលរស់នៅក្រៅប្រទេស ដើម្បីអាចអញ្ជើញមកឱ្យឃើញពីការអភិវឌ្ឍក្រោមម្លប់នៃសុខសន្តិភាពដោយផ្ទាល់ភ្នែក។ | មករា - ធ្នូ | | |
| **វិធានការគន្លឹះទី៧ - បង្កើនភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង** | | | |
| **វិធានការទី២៣ - បង្កើតខ្សែទស្សនកិច្ចស្វែងយល់បេតិកភណ្ឌពិភពលោករបស់កម្ពុជាសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង** | | | |
| ▪ រៀបចំខ្សែទស្សនកិច្ចស្វែងយល់បេតិកភណ្ឌពិភពលោកនៅខេត្តសៀមរាបសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង។ | មករា - ធ្នូ | - ក្រសួងទេសចរណ៍/ក.ផ.ផ. | - រដ្ឋបាលខេត្តសៀមរាប<br>- អាជ្ញាធរជាតិអប្សរា<br>- វិស័យឯកជន |

| វិធានការទី២៤- ពង្រឹង និងបង្កើនការផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរបរទេសផ្ទៃក្នុង | | | |
|---|---|---|---|
| ▪ ជំរុញ និងលើកទឹកចិត្តឱ្យមានដំណើរកម្សាន្តទេសចរណ៍សម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុង តាមរយៈការរៀបចំកញ្ចប់ទស្សនកិច្ចទេសចរណ៍បេតិកភណ្ឌពិភពលោក ដោយយករមណីយដ្ឋានអង្គរជាអ័ក្សស្នូល ផ្សារភ្ជាប់ជាមួយប្រាសាទព្រះវិហារ ប្រាសាទសំបូរព្រៃគុក និងរមណីយដ្ឋានទេសចរណ៍សំខាន់ៗផ្សេងទៀត ដោយអាចឱ្យភ្ញៀវទេសចរបរទេសផ្ទៃក្នុងទស្សនាបានច្រើនដង ក្នុងតម្លៃសមរម្យ | មករា-ធ្នូ | - ក្រសួងទេសចរណ៍/ ក.ផ.ផ. | -រដ្ឋបាលខេត្តសៀមរាប<br>-វិស័យឯកជន |
| ▪ បន្តការបង្កើនភាពទាក់ទាញសម្រាប់ភ្ញៀវទេសចរបរទេសផ្ទៃក្នុងមកកាន់ខេត្តសៀមរាប ដោយផ្តោតលើការផ្តល់ជម្រើសបន្ថែមនៃប្រភេទបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ ដូចករណីដែលគ្រឹះស្ថានអង្គរបានដាក់ចេញនូវកម្មវិធីស្នើសុំបណ្ណចូលទស្សនារមណីយដ្ឋានអង្គរ និងប្រាសាទកោះកេរ ដោយឥតបង់ថ្លៃ ដែលអាចធ្វើតាមអនឡាញ សម្រាប់ជនបរទេសដែលបានរស់នៅក្នុងប្រទេសកម្ពុជាចាប់ពី២ឆ្នាំឡើងទៅ។ | មករា-ធ្នូ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ / គ្រឹះស្ថានអង្គរ | -ក្រសួងទេសចរណ៍<br>-អាជ្ញាធរជាតិអប្សរា<br>-រដ្ឋបាលខេត្តសៀមរាប |

**សរុបរួម** វិធានការគន្លឹះមានចំនួន **៧** និងវិធានការចំនួន **២៤** ចែកជា **៧៣**សកម្មភាព។

**សម្គាល់ : អក្សរកាត់ឈ្មោះស្ថាប័ន**

- **ក.ផ.ផ.** = ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា
- **ក.អ.ក.** = ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- **អ.អ.** = អគ្គនាយកដ្ឋានអន្តោប្រវេសន៍
- **ន.ប.ជ.ក.** = អគ្គស្នងការដ្ឋាននគរបាលជាតិ
- **ឧ.ជ.ភ.គ.** = ឧទ្យានជាតិភ្នំគូលែន
- **ក្រ.ពាក់ព័ន្ធ** = ក្រសួង - ស្ថាប័នពាក់ព័ន្ធ
- **ស.ស.យ.ក.** = សហភាពសហព័ន្ធយុវជនកម្ពុជា
- **គ.ជ.អ.ក.** = គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា
- **គ.ជ.ភ.១ ផ.១** = គណៈកម្មាធិការជាតិជំរុញចលនា ភូមិ១ ផលិតផល១
- **គ.អ.ទ.ស.** = គណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ
- **គ.ស.ធ.ឱ.** = គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឱជីថល
- **គ.ជ.ប.អ.** = គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ
- **គ.ជ.វ.ទ.** = គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត
- **គ.អ.ច.ទ.** = គណៈកម្មការអន្តរក្រសួងដើម្បីសម្រួលការធ្វើដំណើរនិងដឹកជញ្ជូនភ្ញៀវទេសចរ និងអ្នកដំណើរនៅតំបន់ច្រកទ្វារព្រំដែនអន្តរជាតិនិងច្រកទ្វារអន្តរជាតិទូទាំងប្រទេស
- **គ.អ.រ.ព.ស.** = គណៈកម្មការអន្តរក្រសួងដើម្បីរៀបចំនិងអភិវឌ្ឍទីប្រជុំជនរុនតាឯក និងទីប្រជុំជនពាក់ស្នែង ខេត្តសៀមរាប
- Sub-DMO = អង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក